00541173

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ឯកសារ/No: D263/2/6

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

តាមនាមប្រជារាស្ត្រខ្មែរ និងតាមនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពី
ការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម
ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/កសចស(អបជ៤១)

ចំពោះមុខ៖ ចៅក្រម ប្រាក់ គឹមសាន ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម នេ៎យ ថុល
ចៅក្រម Catherine MARCHI-UHEL
ចៅក្រម ហួត វុទ្ធី

កាលបរិច្ឆេទ៖ ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១០

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 25 / 06 / 2010
ម៉ោង (Time/Heure): 11:30
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Ratanak

---

សាធារណៈ

សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត
សម្រេចបដិសេធសំណើសុំឲ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាពកិច្ចស៊ើបសួរទាំងអស់ (D263/1)

---

__សហព្រះរាជអាជ្ញា__

លោកស្រី ជា លាង

លោក Andrew CAYLEY

__ជនត្រូវចោទ__

លោក អៀង ធីរិទ្ធ

__សហមេធាវីការពារក្តីជនត្រូវចោទ__

លោក ផាត់ ពៅស៊ាង

កញ្ញា Dianna ELLIS QC

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 25 / 06 / 2010
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

<u>**សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**</u>

លោក នី ច័ន្ទឌី

លោក Mahdev MOHAN

កញ្ញា Lima NGUYEN

លោក គឹម ម៉េងឃី

លោកស្រី ម៉ុច សុវណ្ណារី

លោកស្រី Elizabeth-Joelle RABESANRATANA

លោកស្រី Annie DELAHAIE

លោក Philippe CANONNE

លោកស្រី Martine JACQUIN

លោកស្រី Fabienne TRUSSES-NAPROUS

លោកស្រី Françoise GAUTRY

លោកស្រី Isabelle DURAND

លោកស្រី Christine MARTINEAU

លោកស្រី Laure DESFORGES

លោក Ferdinand DJAMMEN-NZEPA

លោក ឡោ ជុនធី

លោកស្រី ស៊ីន សុវន

លោក សំ សុគង់

លោក ហុង គឹមសួន

លោក គង់ ពិសី

លោក គង់ ហេង

លោកស្រី Silke STUDZINSKY

លោក Olivier BAHOUGNE

លោកស្រី Marie GUIRAUD

លោក Partirck BAUDOUIN

លោកស្រី ជេត វណ្ណលី

លោក ពេជ អង្គ

លោក Julien RIVET

លោក Pascal AUBOIN

លោក យុង ផានិត

<u>**សហចៅក្រមស៊ើបអង្កេត**</u>

លោក យូ ប៊ុនឡេង

លោក Marcel LEMONDE

<u>**ដើមបណ្តឹងរដ្ឋប្បវេណីដែលគ្មានអ្នកតំណាង**</u>

**អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អវតក”) បានទទួល (“បណ្តឹងឧទ្ធរណ៍របស់សហមេធាវីការពារក្តី ប្រឆាំងនឹងដីកាសម្រេចបដិសេធសំណើសុំឱ្យធ្វើមោឃភាព និងសំណើសុំផ្អាកដំណើរការនីតិវិធីដោយសារមូលហេតុរំលោភនីតិវិធី ដែលបានប្តឹងដោយ អៀង ធីរិទ្ធ[១] “បណ្តឹងឧទ្ធរណ៍ស្តីពីសំណើសុំឱ្យធ្វើមោឃភាព” និង “បណ្តឹងឧទ្ធរណ៍ស្តីពីការរំលោភនីតិវិធី” ដែលត្រូវបានរួមបញ្ចូលគ្នាជា “បណ្តឹងឧទ្ធរណ៍រួម” ដែលបានដាក់ដោយសហមេធាវីការពារក្តីរបស់ជនត្រូវចោទឈ្មោះ អៀង ធីរិទ្ធ (“ជនត្រូវចោទ” ឬ“ដើមបណ្តឹងឧទ្ធរណ៍”) កាលពីថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ ២០១០ កន្លងមកនេះ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត “សចស” បដិសេធសំណើសុំឱ្យធ្វើមោឃភាព និងសំណើសុំផ្អាកដំណើរការនីតិវិធីដោយសារមូលហេតុរំលោភនីតិវិធី ដែលត្រូវបានប្តឹងដោយ អៀង ធីរិទ្ធ[២])។ (“ដីកាសម្រេចបដិសេធសំណើសុំឱ្យធ្វើមោឃភាពដែលរងការជំទាស់” និង “ដីកាសម្រេចអំពីការរំលោភនីតិវិធីដែលរងការជំទាស់” ត្រូវបានសម្រេចរួមគ្នាជា (“ដីកាសម្រេចរួមដែលរងការជំទាស់”) ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៩ និងបានជូនដំណឹងនៅថ្ងៃទី៤ ខែមករា ឆ្នាំ២០១០។

---

[១] បណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តីប្រឆាំងនឹង “ដីកាសម្រេចបដិសេធសំណើសុំឱ្យធ្វើមោឃភាពកិច្ចស៊ើបសួរ និងសំណើសុំផ្អាកកិច្ចស៊ើបសួរ ដោយមូលហេតុរំលោភនីតិវិធី ដែលធ្វើឡើងដោយ អៀង ធីរិទ្ធ (D263/1) នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៩ ចុះថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០១០ ឯកសារ D263/2/1 (“បណ្តឹងឧទ្ធរណ៍ស្តីពីសំណើសុំធ្វើមោឃភាព”) និងបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តីប្រឆាំងនឹង “ដីកាសម្រេចបដិសេធសំណើសុំមោឃភាព និងសំណើសុំផ្អាកកិច្ចស៊ើបសួរដោយមូលហេតុរំលោភនីតិវិធី ដែលធ្វើឡើងដោយជនត្រូវចោទ អៀង ធីរិទ្ធ (D264/1) នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៩ ចុះថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០១០, ឯកសារ D264/2/1 (“បណ្តឹងឧទ្ធរណ៍ស្តីពីការរំលោភនីតិវិធី”) (ដែលត្រូវបានរួមបញ្ចូលគ្នាជា “បណ្តឹងឧទ្ធរណ៍រួម”) ។

[២] ដីកាសម្រេចបដិសេធសំណើសុំឱ្យធ្វើមោឃភាពកិច្ចស៊ើបសួរ និងសំណើសុំព្យួរកិច្ចស៊ើបសួរ ដោយមូលហេតុរំលោភនីតិវិធីឡើយដោយ អៀង ធីរិទ្ធ នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៩ និងដាក់ជូននៅថ្ងៃទី៤ ខែមករា ឆ្នាំ២០១០ ឯកសារ D263/1 (“ដីកាសម្រេចបដិសេធសំណើសុំឱ្យធ្វើមោឃភាពកិច្ចស៊ើបសួរដែលរងការជំទាស់”) និង“ដីកាសម្រេចបដិសេធសំណើសុំមោឃភាព និងសំណើសុំផ្អាកកិច្ចស៊ើបសួរដោយមូលហេតុរំលោភនីតិវិធី ដែលធ្វើឡើងដោយជនត្រូវចោទ អៀង ធីរិទ្ធនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៩ ឯកសារ D264/1 (“ដីកាសម្រេចអំពីការរំលោភនីតិវិធីដែលរងការជំទាស់”) (ដែលត្រូវបានសម្រេចរួមគ្នាជា “ដីកាសម្រេចរួមដែលរងការជំទាស់”)។

00541176



## I. ការពិចារណាជាបឋម

១. អង្គបុរេជំនុំជម្រះសង្កេតឃើញថា ការិយាល័យសហចៅក្រមស៊ើបអង្កេតបានចេញដីកាសម្រេចរួមគ្នាតែមួយ និងបានដាក់ឯកសារដូចគ្នានេះ ទាំងនៅក្នុងដីកាសម្រេចបដិសេធសំណើសុំឱ្យធ្វើមោឃភាពដែលរងការជំទាស់ និង ដីកាសម្រេចអំពីការរំលោភនីតិវិធីដែលរងការជំទាស់ ដែលនាំឱ្យដីកាសម្រេចរួមគ្នាដែលរងការជំទាស់ ត្រូវបានយកមកប្រើប្រាស់រួមគ្នានៅក្នុងសំណើសុំជាបន្តបន្ទាប់នៅចំពោះមុខអង្គបុរេជំនុំជម្រះ។ ដោយសារទាំងបណ្តឹងឧទ្ធរណ៍ស្តីពីសំណើសុំឱ្យធ្វើមោឃភាព ទាំងបណ្តឹងឧទ្ធរណ៍ស្តីពីការរំលោភនីតិវិធី បានសំអាងទៅលើមូលហេតុស្រដៀងគ្នានៃការប្តឹងឧទ្ធរណ៍ នោះផលវិបាកនៃការអនុវត្តមានលក្ខណៈខុសគ្នា ដោយសំណើសុំឱ្យធ្វើមោឃភាពកំពុងត្រូវបានដកចេញពីសំណុំរឿង ដែលខុសពីសំណើសុំផ្អាកដំណើរការនីតិវិធីជាអចិន្ត្រៃយ៍ គឺជាសំណូមពរទាក់ទងនឹងការរកឃើញថាមានការរំលោភនីតិវិធី។ អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះនឹងសម្រេចទៅលើបណ្តឹងឧទ្ធរណ៍រួមនេះ នៅក្នុងសាលដីកាដាច់ដោយឡែកពីគ្នា ដើម្បីជៀសវាងកុំឱ្យមានការច្រឡូកច្របល់។ សាលដីកានេះនឹងគ្របដណ្តប់តែទៅលើសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ចំពោះបណ្តឹងឧទ្ធរណ៍ស្តីពីសំណើសុំឱ្យធ្វើមោឃភាពតែមួយប៉ុណ្ណោះ។

## II. ប្រវត្តិនីតិវិធី និងសេចក្តីសង្ខេបនៃសំណើសុំនានា

២. នៅថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០០៩ សហមេធាវីរបស់ដើមបណ្តឹងឧទ្ធរណ៍បានដាក់សំណើសុំពីរ៖ (i) "សំណើសុំទៅសហចៅក្រមស៊ើបអង្កេត ឱ្យស្នើសុំអង្គបុរេជំនុំជម្រះធ្វើមោឃភាពកិច្ចស៊ើបសួរ" ("សំណើសុំឱ្យធ្វើមោឃភាពកិច្ចស៊ើបសួរ"[៣]) និង (ii) "សំណើរបស់មេធាវីការពារក្តីសុំឱ្យផ្អាកដំណើរការនីតិវិធី ដោយសារមូលហេតុរំលោភនីតិវិធី" ("សំណើសុំស្តីពីការរំលោភនីតិវិធី"[៤])។ សំណើសុំឱ្យធ្វើមោឃភាពកិច្ចស៊ើបសួរ បានស្នើការិយាល័យសហចៅក្រមស៊ើបអង្កេត(កសចស)

---

[៣] សំណើសុំទៅសហចៅក្រមស៊ើបអង្កេត ស្នើសុំឱ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាពកិច្ចស៊ើបសួរ ចុះថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០០៩ ឯកសារលេខ D263 ("សំណើសុំឱ្យធ្វើមោឃភាពកិច្ចស៊ើបសួរ")។

[៤] សំណើសុំរបស់មេធាវីការពារក្តីសុំឱ្យផ្អាកដំណើរការនីតិវិធី ដោយសារមូលហេតុរំលោភនីតិវិធី ចុះថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០០៩ ឯកសារលេខ D264 ("សំណើសុំស្តីពីការរំលោភនីតិវិធី")។

“សុំឱ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាពកិច្ចស៊ើបសួរទាំងអស់ ដោយសារមូលហេតុនៃការរំលោភបទប្បញ្ញត្តិនីតិវិធីមួយចំនួន[5]” ថា “បានរំលោភសិទ្ធិរបស់ជនត្រូវចោទក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ និងអនាគតិ[6]” ដូចត្រូវបានធានាដោយមាត្រា១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR[7]) និងត្រូវបានដាក់បញ្ចូលក្នុងវិធាន ២១ នៃវិធានផ្ទៃក្នុង។

៣. សហមេធាវីការពារក្តីរបស់ជនត្រូវចោទបានចោទប្រកាន់ថាដោយ៖ (i) ការមិនមានអនាគតិ[8] (ii) ការរំលោភនៃអាណត្តិលើភាពដាច់ដោយឡែកពីគ្នា រវាងអាជ្ញាធរដែលទទួលបន្ទុកធ្វើការចោទប្រកាន់ និងអាជ្ញាធរដែលទទួលបន្ទុកធ្វើការវិនិច្ឆ័យទោស និងការមិនមានឯករាជ្យភាព[9] (iii) ការលាក់បំបាំងព័ត៌មានដោយ“ភាគីអន្តរជាតិ” មិនឱ្យ“ភាគីជាតិ”នៃ អវតក ដឹង[10] និង(iv) ការរំលោភលើភាពសម្ងាត់ ដោយសារក្រុមថតខ្សែភាពយន្តឯកសារមួយក្រុមត្រូវបានអនុញ្ញាតឱ្យថតការស្តាប់ចម្លើយសាក្សីម្នាក់[11]។

៤. នៅថ្ងៃទី៤ ខែមករា ឆ្នាំ២០១០ សចស បានចេញដីកាសម្រេចបដិសេធសំណើសុំឱ្យធ្វើមោឃភាពដែលរងការជំទាស់ បានប្រកាសថា “មិនមានអ្វីត្រូវយកមកធ្វើយុត្តិកម្ម” ដើម្បីស្នើសុំឱ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាពដំណើរការនីតិវិធីនោះទេ ដោយសារថា “មិនមានកំហុសនីតិវិធី មិនមានការរំលោភសិទ្ធិណាមួយរបស់មេធាវីការពារក្តីដូចមានចែងក្នុង [ICCPR] ឬវិធាន ២១ នៃវិធានផ្ទៃក្នុងនោះទេ”[12]។ ដីកាសម្រេចបដិសេធសំណើសុំឱ្យធ្វើមោឃភាពដែលរងការជំទាស់បានបដិសេធ

---

[5] សំណើសុំឱ្យធ្វើមោឃភាពកិច្ចស៊ើបសួរ កថាខណ្ឌ១។

[6] សំណើសុំឱ្យធ្វើមោឃភាពកិច្ចស៊ើបសួរ កថាខណ្ឌ៣ និង កថាខណ្ឌ៥២ ។

[7] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ, សេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិលេខ 2200A [XX1] ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦ មាត្រា១៤។

[8] សំណើសុំឱ្យធ្វើមោឃភាពកិច្ចស៊ើបសួរ កថាខណ្ឌ១២ ដល់ កថាខណ្ឌ២២ ។

[9] សំណើសុំឱ្យធ្វើមោឃភាពកិច្ចស៊ើបសួរ កថាខណ្ឌ២៣ ដល់ កថាខណ្ឌ៣០ ។

[10] សំណើសុំឱ្យធ្វើមោឃភាពកិច្ចស៊ើបសួរ កថាខណ្ឌ៣១ ដល់ កថាខណ្ឌ៣៩ ។

[11] ណើសុំឱ្យធ្វើមោឃភាពកិច្ចស៊ើបសួរ កថាខណ្ឌ៤០ ដល់ កថាខណ្ឌ៥១ ។

[12] ដីកាសម្រេចបដិសេធសំណើសុំឱ្យធ្វើមោឃភាពដែលរងការជំទាស់ កថាខណ្ឌ៤២ ។

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

មូលហេតុទាំងបួនដែលបានលើកឡើងនៅក្នុងសំណើសុំឱ្យធ្វើមោឃភាព ដោយសារមូលហេតុថា៖

(១) ការចោទប្រកាន់ពីភាពលំអៀង មិនអាចរួចផុតពីបន្ទុកនៃការស្វែងរកភស្តុតាងនោះទេ[១៣]។

(២) សហចៅក្រមស៊ើបអង្កេតបានពិចារណាថា ទោះជាតាមមធ្យោបាយណាក៏ដោយ សេចក្តីថ្លែងការណ៍ច្របូកច្របល់របស់លោក Bastin មិនអាចមានទម្ងន់ទៅលើការចោទប្រកាន់ដែលថា បុគ្គលិកមួយរូបនៅក្នុងការិយាល័យសហព្រះរាជអាជ្ញា (កសព) បានផ្តល់ឯកសារមួយច្បាប់ទៅឱ្យភាគីអន្តរជាតិនៃ កសចស នោះទេ ដោយសារការលើកឡើងពីទីកន្លែងជាក់លាក់មួយចំនួនដែលមិនមានបញ្ជាក់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម គឺមិនមានខ្លឹមសារអ្វីឡើយ[១៤]។

(៣) "ក្នុងការអនុវត្តជាក់ស្តែងនៅ កសចស រាល់ការងារដែលបានធ្វើជាឯកតោភាគីដោយភាគីជាតិ ឬភាគីអន្តរជាតិ ត្រូវបានចាត់ទុកថាជាការងារត្រៀមរៀបចំតែប៉ុណ្ណោះ ហើយ [...] រាល់កិច្ចស៊ើបសួរទាំងអស់ត្រូវបានបំពេញរួមគ្នា"[១៥] និង

(៤) "ផ្នែកមួយនៃកិច្ចសន្យាដែលបានចុះហត្ថលេខាជាមួយការិយាល័យរដ្ឋបាលនៃ អវតក ក្រុមអ្នកថតខ្សែភាពយន្តឯកសារមួយក្រុម ត្រូវបានអនុញ្ញាតឱ្យផលិតខ្សែភាពយន្តមួយដែលមានគោលដៅអប់រំ និងប្រវត្តិសាស្ត្រ"[១៦] ដែល "បានទទួលការយល់ព្រមពីសហចៅក្រមស៊ើបអង្កេតទាំងពីររូប" ហើយនឹង "ចាក់ផ្សាយ ឬផ្សព្វផ្សាយបាន បន្ទាប់ពីការជំនុំជម្រះក្តីទាំងអស់ត្រូវបានបញ្ចប់រួចរាល់ហើយតែប៉ុណ្ណោះ [...]"[១៧]។

៥. សហមេធាវីការពារក្តីរបស់ជនត្រូវចោទបានដាក់បណ្តឹងឧទ្ធរណ៍របស់ខ្លួន នៅថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០១០។ បណ្តឹងឧទ្ធរណ៍ស្តីពីសំណើសុំឱ្យធ្វើមោឃភាព លើកឡើងពីមូលហេតុមួយចំនួននៃបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចបដិសេធសំណើសុំឱ្យធ្វើមោឃភាព ដែលរងការជំទាស់ចោទប្រកាន់ថា៖ (i) សចស បានអនុវត្តបទដ្ឋាននៃការបង្ហាញភស្តុតាងមិនបានត្រឹមត្រូវ នៅក្នុងការ

---

[១៣] ដីកាសម្រេចបដិសេធសំណើសុំឱ្យធ្វើមោឃភាព ដែលរងការជំទាស់ កថាខណ្ឌ១៣ ដល់ ១៤ ។

[១៤] ដីកាសម្រេចបដិសេធសំណើសុំឱ្យធ្វើមោឃភាព ដែលរងការជំទាស់ កថាខណ្ឌ២៦ ។

[១៥] ដីកាសម្រេចបដិសេធសំណើសុំឱ្យធ្វើមោឃភាព ដែលរងការជំទាស់ កថាខណ្ឌ២១ ។

[១៦] ដីកាសម្រេចបដិសេធសំណើសុំឱ្យធ្វើមោឃភាព ដែលរងការជំទាស់ កថាខណ្ឌ២៣។

[១៧] ដីកាសម្រេចបដិសេធសំណើសុំឱ្យធ្វើមោឃភាព ដែលរងការជំទាស់ កថាខណ្ឌ២៤។

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. * C.E.T.C.

00541179



វាយតម្លៃទូទៅរបស់ខ្លួនអំពីសំណើសុំឱ្យធ្វើមោឃភាព ដោយការពិនិត្យទៅលើអង្គសេចក្តីនៃសំណើសុំនេះ ជាជាងការអនុវត្ត *បទដ្ឋាននៃភស្តុតាងបឋម* (*prima facie* test)[១៨] ទៅវិញ (ii) សចស ក៏បានអនុវត្តបទដ្ឋាននៃការបង្ហាញភស្តុតាងមិនបានត្រឹមត្រូវ នៅក្នុងការវាយតម្លៃទៅលើភស្តុតាងដែលបានលើកឡើងនៅក្នុងសំណើសុំឱ្យធ្វើមោឃភាព[១៩] (iii) សចស ខកខានមិនបានដោះស្រាយបញ្ហាមួយចំនួនដែលបានលើកឡើងដោយមេធាវីការពារក្តី នៅក្នុងសំណើសុំឱ្យធ្វើមោឃភាព[២០] (iv) សចស បានបកស្រាយ និងអនុវត្តវិធាន ៥៦(២)(ខ) នៃវិធានផ្ទៃក្នុងខុស[២១] (v) សចស ខកខានមិនបានដោះស្រាយទឡ្ហីករណ៍ជាក់លាក់អំពីការថតខ្សែភាពយន្តឯកសារដោយលួចលាក់ខុសច្បាប់ ដែលមេធាវីការពារក្តីបានលើកឡើង "ដែលកាន់តែបង្ហាញឱ្យឃើញថែមទៀតនូវការបកស្រាយវិធាន ៥៦(២)(ខ) នៃវិធានផ្ទៃក្នុងមិនបានត្រឹមត្រូវ[២២] (vi) សចស មិនបានបដិសេធអំពីការទទួលយកឯកសារពីអ្នកស៊ើបអង្កេតមួយរូបនៅក្នុង កសព នោះទេ[២៣] និង (vii) ផ្នែកមួយនៃដីកាសម្រេចបដិសេធសំណើសុំឱ្យធ្វើមោឃភាព "ត្រូវបានធ្វើឡើងដោយលោកចៅក្រម Lemonde តែម្នាក់ឯង ដោយមិនមានការសហការពីលោកចៅក្រម យូ ប៊ុនឡេង នោះទេ" ដែលនេះគឺ "ជាការរំលោភកាតព្វកិច្ចរបស់ កសចស ដែលត្រូវបំពេញកិច្ចរួមគ្នា"[២៤]។ បណ្តឹងឧទ្ធរណ៍ស្តីពីសំណើសុំឱ្យធ្វើមោឃភាព ស្នើសុំឱ្យអង្គបុរេជំនុំជម្រះ ច្រានចោលដីកាសម្រេចបដិសេធសំណើសុំឱ្យធ្វើមោឃភាពដែលរងការជំទាស់ និងស្នើសុំឱ្យពិចារណាទទួលយកសំណើសុំឱ្យធ្វើមោឃភាពនេះ។

៦. នៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១០ សហព្រះរាជអាជ្ញាបានដាក់ចម្លើយតបរួមរបស់ខ្លួន "ចម្លើយតប

[១៨] បណ្តឹងឧទ្ធរណ៍ស្តីពីសំណើសុំឱ្យធ្វើមោឃភាព កថាខណ្ឌ២៤ ដល់ ៣៣។

[១៩] បណ្តឹងឧទ្ធរណ៍ស្តីពីសំណើសុំឱ្យធ្វើមោឃភាព កថាខណ្ឌ៣៤ ដល់ ៤២។

[២០] បណ្តឹងឧទ្ធរណ៍ស្តីពីសំណើសុំឱ្យធ្វើមោឃភាព កថាខណ្ឌ៤៣ ដល់ ៥៤។

[២១] បណ្តឹងឧទ្ធរណ៍ស្តីពីសំណើសុំឱ្យធ្វើមោឃភាព កថាខណ្ឌ៥៥ ដល់ ៦៤។

[២២] បណ្តឹងឧទ្ធរណ៍ស្តីពីសំណើសុំឱ្យធ្វើមោឃភាព កថាខណ្ឌ៦៩។សូមមើលពីកថាខណ្ឌ៦៥ ដល់ ៧០ ផងដែរ។

[២៣] បណ្តឹងឧទ្ធរណ៍ស្តីពីសំណើសុំឱ្យធ្វើមោឃភាព កថាខណ្ឌ៧១ ដល់ ៧៦ ។

[២៤] បណ្តឹងឧទ្ធរណ៍ស្តីពីសំណើសុំឱ្យធ្វើមោឃភាព កថាខណ្ឌ៧៧។ សូមមើលពីកថាខណ្ឌ៧៨ ដល់ ៨២ ផងដែរ។

ECCC PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

របស់សហព្រះរាជអាជ្ញា"[២៥] ទៅនឹងបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តីស្តីពីសំណើសុំឱ្យធ្វើមោឃភាព និងបណ្តឹងឧទ្ធរណ៍ស្តីពីការរំលោភនីតិវិធី។ សហព្រះរាជអាជ្ញាស្នើសុំឱ្យអង្គបុរេជំនុំជម្រះច្រានចោលបណ្តឹងឧទ្ធរណ៍ទាំងពីរ និងតម្កល់ទុកដីកាសម្រេចរបស់ សចស ដែលរងការជំទាស់នេះ ដោយហេតុថា បណ្តឹងឧទ្ធរណ៍ទាំងពីរ និងសំណើសុំទាំងនេះ៖

> (i) ផ្តល់ភស្តុតាងដែលមិនអាចឱ្យជឿបាន មិនចង្អុលបង្ហាញនូវអ្វីដែលខ្លួនចង់បញ្ជាក់អះអាង និង/ឬ មិនបង្ហាញឱ្យឃើញពីការរំលោភសិទ្ធិរបស់ជនត្រូវចោទនោះទេ (ii) ខកខានមិនបានបំពេញនូវបន្ទុកដ៏ខ្ពស់បំផុតអំពីការរំលោភទ្រឹស្តីនៃដំណើរការនីតិវិធី និងបទដ្ឋានសម្រាប់ការធ្វើមោឃភាពកិច្ចស៊ើបសួរទាំងអស់ ដែលជាដំណោះស្រាយតាមផ្លូវតុលាការដ៏តឹងរ៉ឹងបំផុត ដែលត្រូវបានបំរុងទុកសម្រាប់កាលៈទេសៈដ៏ធ្ងន់ធ្ងរបំផុតនោះ (iii) លើកឡើងអំពីយោបល់ផ្សេងៗដែលមិនមានមូលដ្ឋានច្បាស់លាស់ទាក់ទងនឹងកង្វះកិច្ចសហប្រតិបត្តិការរវាងសហចៅក្រមជាតិ និងអន្តរជាតិ ដែលជាបញ្ហាមិនពាក់ព័ន្ធ មិនសមហេតុផល ឬក៏គ្រាន់បើជាងដែរ ប្រសិនបើគេបានលើកឡើងពីយន្តការដោះស្រាយវិវាទដែលត្រូវបានដោះស្រាយកាន់តែសមស្រប ដែល សចស អាចរកបាននៅក្រោមវិធាន ៧២ នៃវិធានផ្ទៃក្នុងនោះ (iv) ខកខានមិនបានបញ្ជាក់អះអាងថា នៅក្នុងការចេញដីកាសម្រេចរបស់ខ្លួន សចស ពិតជាបានអនុវត្តច្បាប់គ្រប់គ្រងខុសមែននោះ[២៦]។

សហព្រះរាជអាជ្ញាកត់សម្គាល់ឃើញថា វិធាន៤៨ នៃវិធានផ្ទៃក្នុងចែងថា ការធ្វើមោឃភាព "កិច្ចស៊ើបសួរ ឬកិច្ចរបស់អង្គជំនុំជម្រះ អាចត្រូវបានចាត់ទុកជាមោឃៈ តែចំពោះករណីមិនគោរពវិធានបញ្ញត្តិដែលធ្វើឱ្យប៉ះពាល់ដល់សិទ្ធិរបស់ភាគីតែប៉ុណ្ណោះ"[២៧]។ សហព្រះរាជអាជ្ញាក៏កត់សម្គាល់ឃើញផងដែរថា វិសាលភាពនៃការធ្វើមោឃភាពគឺថិតក្នុងរង្វង់ឆន្ទានិសិទ្ធិរបស់ចៅក្រម ដូចមាន

---

[២៥] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តីប្រឆាំងនឹង "ដីកាសម្រេចបដិសេធសំណើសុំមោឃភាព និងសំណើសុំផ្អាកកិច្ចស៊ើបសួរដោយមូលហេតុរំលោភនីតិវិធីធ្វើឡើងដោយ អៀង ធីរិទ្ធ" (D263/1 និង D264/1) នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៩ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១០ ឯកសារ D263/2/2 ("ចម្លើយតបរបស់សហព្រះរាជអាជ្ញា")។ សូមមើលជាពិសេសត្រង់កថាខណ្ឌទី៤, ដែលក្នុងនោះសហព្រះរាជអាជ្ញាពន្យល់ថាការឆ្លើយតបរបស់ខ្លួនគឺមានបំណងផ្តល់ការអនុវត្តទាំងចំពោះបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចបដិសេធសំណើសុំមោឃភាពនិងសំណើសុំផ្អាកកិច្ចស៊ើបសួរដោយមូលហេតុរំលោភនីតិវិធី។

[២៦] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ៣។

[២៧] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ១១។



អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

ចែងអំពីមោឃភាពមានកម្រិត ក្នុងវិធាន៧៦(៥) នៃវិធានផ្ទៃក្នុង[២៨]។ ហេតុដូច្នេះ "មានតែក្នុងកាលៈទេសៈ*ពិសេស*តែប៉ុណ្ណោះ ដែលកិច្ចដំណើរការនីតិវិធី ឬកិច្ចស៊ើបសួរទាំងមូលអាចត្រូវបានចាត់ទុកជាមោឃៈចំពោះកំហុសនីតិវិធី ដោយសារកំហុសនោះអាចធ្វើឱ្យប៉ះពាល់ដល់កិច្ចស៊ើបសួរគ្រប់ផ្នែកទាំងអស់[២៩]។

៧. នៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១០ អង្គបុរេជំនុំជម្រះបានចេញ "សេចក្តីសម្រេចអំពីការកំណត់លើបណ្តឹងឧទ្ធរណ៍ដោយផ្អែកលើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ និងសេចក្តីណែនាំឱ្យធ្វើការឆ្លើយតប"[៣០] ដោយបដិសេធសំណើរបស់សហមេធាវីការពារក្តីរបស់ជនត្រូវចោទសុំឱ្យមានសវនាការជាសាធារណៈ និងណែនាំឱ្យសហមេធាវីការពារក្តីឱ្យឆ្លើយតបទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញា នៅក្នុងពេលវេលាកំណត់ដែលមានចែងបញ្ជាក់ក្នុងមាត្រា៨.៤ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ[៣១]។

៨. នៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១០ សហមេធាវីការពារក្តីបានដាក់ "ការឆ្លើយតបរបស់ខ្លួនទៅនឹងចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា ឆ្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តីប្រឆាំងនឹងដីកាសម្រេចអំពីមោឃភាព និងការរំលោភនីតិវិធី" (ហៅថា "ការឆ្លើយតប")[៣២]។ ការឆ្លើយតបរបស់មេធាវីការពារក្តីអះអាងថា៖ (i) រាល់កិច្ចស៊ើបសួរទាំងអស់ត្រូវចាត់ទុកជាមោឃៈដោយសារកំហុសនីតិវិធីនេះបានធ្វើឱ្យប្រឡាក់ប្រឡូកដល់ការស៊ើបអង្កេតទាំងមូល[៣៣] ហើយ "ច្បាប់យុត្តិសាស្ត្រប្រទេសបារាំងដែលបានយកមកធ្វើជាសំអាងនៅក្នុងចម្លើយតបរបស់ កសព គឺ

PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C * C.E.T.C

---

[២៨] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ១៣។

[២៩] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ១៤។

[៣០] សេចក្តីសម្រេចអំពីការកំណត់លើបណ្តឹងឧទ្ធរណ៍ ដោយផ្អែកលើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ និងសេចក្តីសន្និដ្ឋានណែនាំឱ្យធ្វើការឆ្លើយតប ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១០ ឯកសារ D263/2/3។

[៣១] សេចក្តីណែនាំអនុវត្តស្តីអំពីការដាក់ឯកសារនៅ អ.វ.ត.ក, អ.វ.ត.ក/០១/វិសោធនកម្មលើកទី៤ មាត្រា៨៤។

[៣២] ចម្លើយតបរបស់មេធាវីការពារក្តីទៅនឹងសេចក្តីសន្និដ្ឋានតបរួមរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តីលើដីកាសម្រេចអំពីការរំលោភនីតិវិធី និងដីកាសម្រេចបដិសេធសំណើសុំឱ្យធ្វើមោឃភាពកិច្ចស៊ើបសួរ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១០ ឯកសារ D263/2/4 (ចម្លើយតបរបស់មេធាវីការពារក្តី)។

[៣៣] ចម្លើយតបរបស់មេធាវីការពារក្តី កថាខណ្ឌ៥។

មិនគ្រប់គ្រាន់នោះទេ[៣៤]" ចំណែកវិធានផ្ទៃក្នុងក៏មិនបានចែងតម្រូវឱ្យមាន "កាលៈទេសៈពិសេសនោះដែរ" ប៉ុន្តែ "ការខ្វះអនាគតិភាព [...] អាចនឹងនាំឱ្យកើតមាននូវកាលៈទេសៈពិសេស[៣៥]" ហើយសហព្រះរាជអាជ្ញាបានយល់ច្រឡំចំពោះ "ដំណោះស្រាយដែលបានស្នើសុំនៅក្នុងបណ្តឹងឧទ្ធរណ៍ទាំងពីររបស់មេធាវីការពារក្តី"[៣៦] (ii) សចស មិនបានផ្តល់ហេតុផលឱ្យបានគ្រប់គ្រាន់នៅក្នុងដីកាសម្រេចដែលរងការជំទាស់ ជាហេតុនាំឱ្យរំលោភសិទ្ធិរបស់ជនត្រូវចោទក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌[៣៧] (iii) សហព្រះរាជអាជ្ញាមិនបានបដិសេធថា ឯកសារមួយច្បាប់ត្រូវបានដោះដូរគ្នារវាង កសព និង កសចស[៣៨] នោះទេ និង (iv) សចស មិនបាន "ត្រួតពិនិត្យឱ្យបានហ្មត់ចត់"ទៅលើក្រុមថតភាពយន្តឯកសារនោះឡើយ[៣៩]។

៩. នៅថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១០ អង្គបុរេជំនុំជម្រះបានប្រកាសថា សេចក្តីសម្រេចនៅបទបញ្ញត្តិក្រោយរបស់ខ្លួននៃបណ្តឹងឧទ្ធរណ៍ ដោយចង្អុលបង្ហាញថា "សាលដីកាដែលមានសំអាងហេតុលើបណ្តឹងឧទ្ធរណ៍នេះ នឹងចេញប្រកាសនៅក្នុងពេលសមស្រប៖

**ហេតុដូច្នេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆន្ទ៖**

**ទទួលយក**បណ្តឹងឧទ្ធរណ៍លើការសុំមោឃភាព។

**តម្កល់**មូលដ្ឋានទីមួយនៃបណ្តឹងឧទ្ធរណ៍លើការសុំមោឃភាព និង**ច្រានចោល**ដីកាសម្រេចលើការសុំមោឃភាពដែលត្រូវបានជំទាស់ ដោយសម្រេចថា បញ្ហានេះនឹងយកមកធ្វើការសម្រេចដោយផ្អែកលើមូលដ្ឋានទាំងឡាយ ដូចបានកំណត់នៅក្នុងសំណើសុំមោឃភាព។

---

[៣៤] ចម្លើយតបរបស់មេធាវីការពារក្តី កថាខណ្ឌ៦។ សូមមើលផងដែរ កថាខណ្ឌ៧-៩។

[៣៥] ចម្លើយតបរបស់មេធាវីការពារក្តី កថាខណ្ឌ១០-១១។

[៣៦] ចម្លើយតបរបស់មេធាវីការពារក្តី កថាខណ្ឌ១២។

[៣៧] ចម្លើយតបរបស់មេធាវីការពារក្តី កថាខណ្ឌ១៣-១៥។

[៣៨] ចម្លើយតបរបស់មេធាវីការពារក្តី កថាខណ្ឌ១៦-១៧។

[៣៩] ចម្លើយតបរបស់មេធាវីការពារក្តី កថាខណ្ឌ១៨-២០។

អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

បដិសេធចោលសំណើសុំមោឃភាពទុកជាឥតបានការ"[៤០]។

## សំអាងហេតុនៃសេចក្តីសម្រេច

## III. ភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍

១០. ដីកាសម្រេចបដិសេធសំណើសុំមោឃភាពដែលរងការជំទាស់នេះ ត្រូវបានជូនដំណឹងនៅថ្ងៃទី៤ ខែមករា ឆ្នាំ២០១០។ ការជូនដំណឹងអំពីការប្តឹងឧទ្ធរណ៍ត្រូវបានដាក់នៅថ្ងៃទី១៤ ខែមករា ឆ្នាំ ២០១០[៤១] ហើយសារណាបណ្តឹងឧទ្ធរណ៍ត្រូវបានដាក់នៅថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០១០។ បណ្តឹងឧទ្ធរណ៍នេះត្រូវបានចាប់ផ្តើមដាក់ទាន់ពេលវេលា។

១១. បណ្តឹងឧទ្ធរណ៍នេះត្រូវបានដាក់ដោយអនុលោមតាមវិធាន៧៦(២) នៃវិធានផ្ទៃក្នុង ដែលមានចែងពីសិទ្ធិប្តឹងឧទ្ធរណ៍ បន្ទាប់ពីសំណើសុំឱ្យអង្គបុរេជំនុំជម្រះអនុវត្តការធ្វើមោឃភាពត្រូវបានបដិសេធរួចមក។ បណ្តឹងឧទ្ធរណ៍ស្នើសុំឱ្យធ្វើមោឃភាព ត្រូវបានយកមកពិចារណានៅក្នុងវិធាន ៧៦(៣)(ឆ) នៃវិធានផ្ទៃក្នុង និងអាចទទួលយកបាន។

## IV. កំហុសអង្គច្បាប់ ដែលបានចោទប្រកាន់ថាធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត នៅពេលពិនិត្យមើលការអនុវត្តដែលស្ថិតនៅក្រោមវិធាន៧៦(២) នៃវិធានផ្ទៃក្នុង (មូលហេតុទី ១)

១២. មូលហេតុទីមួយនៅក្នុងបណ្តឹងឧទ្ធរណ៍ស្តីពីការស្នើសុំឱ្យធ្វើមោឃភាព គឺយោងទៅលើការអះអាងថា សហចៅក្រមស៊ើបអង្កេតបានអនុវត្តបទដ្ឋាននៃការបង្ហាញភស្តុតាងមិនបានត្រឹមត្រូវ នៅពេល

---

[៤០] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតដែលបដិសេធសំណើសុំឱ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាពលើគ្រប់កិច្ចស៊ើបសួរទាំងអស់ (D263/1) ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១០ លេខ៖ D263/2/5 ។

[៤១] សៀវភៅចុះបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តីលោកស្រី អៀង ធីរិទ្ធ ចំពោះដីកាបដិសេធសំណើសុំឱ្យធ្វើមោឃភាពកិច្ចស៊ើបសួរ និងសំណើរសុំព្យួរកិច្ចស៊ើបសួរ ដោយមូលហេតុរំលោភនីតិវិធីធ្វើឡើងដោយ អៀង ធីរិទ្ធ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១០ ឯកសារ D263/2។



E.C.C.C * C.E.T.C. PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

ពិចារណាទៅលើការអនុវត្ត ដោយអនុលោមតាមវិធាន៧៦(២) នៃវិធានផ្ទៃក្នុង។ អនុវិធាននេះចែងថា៖

ក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ នៅពេលដែលភាគីទាំងឡាយយល់ឃើញថា មានផ្នែកណាមួយនៃដំណើរការនីតិវិធីត្រូវបានចាត់ទុកជាមោឃៈ នោះភាគីអាចដាក់ពាក្យសុំដោយបញ្ជាក់ពីមូលហេតុទៅសហចៅក្រមស៊ើបអង្កេតដើម្បីស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេត ប្តឹងទៅអង្គបុរេជំនុំជម្រះស្នើសុំឱ្យធ្វើមោឃភាព។ សហចៅក្រមស៊ើបអង្កេតត្រូវចេញដីកាដែលអាចជាការទទួលយក ឬបដិសេធសំណើសុំភ្លាមៗ តាមដែលអាចធ្វើទៅបាន និងក្នុងគ្រប់ករណីទាំងអស់ ត្រូវធ្វើឡើងមុនពេលចេញដីកាដំណោះស្រាយ។ ដីកាបែបនេះ គឺជាកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍ ដោយអនុលោមតាមវិធានផ្ទៃក្នុងនេះ[៤២]

វិធាន៤៨ នៃវិធានផ្ទៃក្នុង គឺជាការណែនាំអំពីបញ្ហាដែលត្រូវបានចាត់ទុកជាមោឃៈ តែចំពោះករណីមិនគោរពវិធានបញ្ញត្តិតែប៉ុណ្ណោះ។ វិធាន៤៨ នៃវិធានផ្ទៃក្នុងចែងថា៖

កិច្ចស៊ើបសួរ ឬកិច្ចរបស់អង្គជំនុំជម្រះអាចត្រូវបានចាត់ទុកជាមោឃៈ តែចំពោះករណីមិនគោរពវិធានបញ្ញត្តិ ដែលធ្វើឱ្យប៉ះពាល់ដល់សិទ្ធិរបស់ភាគីដែលដាក់ពាក្យសុំតែប៉ុណ្ណោះ[៤៣]។

១៣. នៅក្នុងដីកាសម្រេច សហចៅក្រមស៊ើបអង្កេតបានចង្អុលបង្ហាញខ្លួនឯង ទាក់ទងទៅនឹងការអនុវត្តនៅចំពោះមុខខ្លួន នៅក្នុងលក្ខណៈដូចខាងក្រោមនេះ៖

៨. [...] សហចៅក្រមស៊ើបអង្កេតនឹងធ្វើការឆ្លើយតបរួមគ្នា ចំពោះទឡ្ហីករណ៍ទាំងអស់ដែលបានលើកឡើងដោយមេធាវីការពារក្តី ទាំងនៅក្នុងសំណើសុំឱ្យធ្វើមោឃភាព ទាំងនៅក្នុងសំណើសុំឱ្យផ្អាកនីតិវិធី រួមទាំងអំណះអំណាងរួមគ្នា ឬដាច់ដោយឡែកពីគ្នា អាស្រ័យទៅលើខ្លឹមសារនៃទឡ្ហីករណ៍ដែលបានលើកឡើង។ ដូច្នេះ រាល់អំណះអំណាងដែលមិនបានបញ្ជាក់ថា ជាអំណះអំណាងផ្ទាល់ខ្លួនរបស់សហចៅក្រមស៊ើបអង្កេតណាម្នាក់ទេ នោះវាគឺជាអំណះអំណាងដែលត្រូវបានសម្រេចរួមគ្នាដោយសហចៅក្រមស៊ើបអង្កេតទាំងពីររូប។

[...]

៩. លើកលែងតែមានការចែងយ៉ាងច្បាស់អំពីករណីធ្វើមោឃភាព ដោយសារខុសនឹងទម្រង់វិការៈនីតិវិធី នោះទើបកំហុសនីតិវិធីអាចបណ្តាលឱ្យមានមោឃភាពកិច្ចដំណើរការនីតិវិធីមួយ ឬច្រើន

[៤២] វិធាន៧៦(២) នៃវិធានផ្ទៃក្នុង វិសោធនកម្មលើកទី៥។

[៤៣] វិធាន៤៨ នៃវិធានផ្ទៃក្នុង វិសោធនកម្មលើកទី៥។

បាន ប្រសិនបើមានការអះអាងពីការរំលោភសិទ្ធិរបស់មេធាវីការពារក្តី ដូចមានចែងនៅក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ សិទ្ធិទាំងនេះក៏ត្រូវបានចែងនៅក្នុងវិធាន២១ នៃវិធានផ្ទៃក្នុងផងដែរ។

១០. យោងតាមវិធាន៤៨ នៃវិធានផ្ទៃក្នុង [...] អាស្រ័យហេតុនេះ នៅពេលពិចារណាអំពីសំណើសុំធ្វើមោឃភាព នោះសហចៅក្រមស៊ើបអង្កេតត្រូវ៖

- ពិនិត្យមើលថាតើមានកំហុសនីតិវិធី និង
- ប្រសិនបើមានកំហុសនីតិវិធី ពិនិត្យមើលថាតើកំហុសនេះវាប៉ះពាល់ ឬមិនប៉ះពាល់ដល់សិទ្ធិរបស់ភាគីដែលដាក់ពាក្យសុំដែរឬយ៉ាងណានោះ។

១១. ចំណុចទាំងនេះគឺជាគោលការណ៍ ដែលសហចៅក្រមស៊ើបអង្កេតនឹងពិចារណាទៅលើអង្គសេចក្តីនៃការទាមទាររបស់មេធាវីការពារក្តីនៅក្នុងករណីនេះ[៤៤]។

១៤. នៅត្រង់កថាខណ្ឌ២៦ និង ២៧ នៃបណ្តឹងឧទ្ធរណ៍ស្តីពីសំណើសុំឱ្យធ្វើមោឃភាព ដើមបណ្តឹងឧទ្ធរណ៍លើកឡើងថា៖

២៦. កសចស បានអនុវត្តបទដ្ឋាននៃការបង្ហាញភស្តុតាងមិនត្រឹមត្រូវ។ បទដ្ឋានដែលតម្រូវនៅ កសចស នៅដំណាក់កាលនេះ មិនដូចគ្នានឹងអ្វីដែលបានរៀបរាប់ខាងលើនោះទេ ប៉ុន្តែ ការវាយតម្លៃនៅក្នុងកម្រិតនេះគួរត្រូវបានកម្រិតចំពោះ *បទដ្ឋាននៃភស្តុតាងបឋម* (*prima facie* test) ថាតើអង្គបុរេជំនុំជម្រះត្រូវដោះស្រាយលើសំណើសុំមោឃភាពដែរឬក៏ទេនោះ មានន័យថាតើមូលហេតុដែលភាគីដាក់សំណើសុំបានលើកឡើងនោះ ផ្តល់ភស្តុតាងបានគ្រប់គ្រាន់ដើម្បីធានាឱ្យមានការជឿជាក់ថា មានមូលហេតុសម្រាប់ធ្វើមោឃភាព ដូចដែលភាគីដាក់សំណើសុំ បានលើកឡើងដែរឬយ៉ាងណានោះ។

២៧. *បទដ្ឋាននៃភស្តុតាងបឋម* (*prima facie* test) ឬ "មូលហេតុដើម្បីឱ្យជឿជាក់" ត្រូវបានអនុវត្តចំពោះករណីនេះសម្រាប់ការបញ្ជាក់អះអាងលើការចោទប្រកាន់ នៅ*តុលាការចំពោះកិច្ចនានា* (*ad hoc tribunals*)។ នៅក្នុងការពន្យល់អំពី *បទដ្ឋាននៃភស្តុតាងបឋម* នៅដំណាក់កាលនៃការបញ្ជាក់អះអាងទៅលើការចោទប្រកាន់ ចៅក្រម Sidhwa នៃតុលាការ ICTY បានសន្និដ្ឋាននៅក្នុងរឿងក្តី *Rajic* ថា៖

"ដូច្នេះ ភស្តុតាងមិនចាំបាច់ឱ្យមានលក្ខណៈប្រាកដប្រជា ឬពេញលេញហួសហេតុនោះទេ ប៉ុន្តែ វាត្រូវតែគ្រប់គ្រាន់ ឬសមហេតុផល ដើម្បីធានាឱ្យជឿជាក់បានថា ជនសង្ស័យបានប្រព្រឹត្តបទល្មើសមែននោះ។ ដូច្នេះ ពាក្យថា "ភស្តុតាងគ្រប់គ្រាន់" មិនមានន័យថា "ភស្តុតាងពេញលក្ខណៈ" ឬ

---

[៤៤] ដីកាសម្រេចបដិសេធសំណើសុំឱ្យធ្វើមោឃភាពដែលរងការជំទាស់ កថាខណ្ឌ៨-១១។



PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C. C.E.T.C.

"ភស្តុតាងហួសពីវិមតិសង្ស័យនោះទេ"[៤៥]។

១៥. នៅក្នុងចម្លើយតប សហព្រះរាជអាជ្ញាបានលើកឡើងថា៖

២០."នៅពេលដែលវិធាន ៧៦(២) និងវិធាន៧៦(៤)នៃវិធានផ្ទៃក្នុង ចែងថា មោឃភាពលើពាក្យសុំត្រូវតែមានបញ្ជាក់មូលហេតុ និងលើកឡើងនូវទឡ្ហីករណ៍នានាដើម្បីឱ្យ អបជ អាចទទួលយក ឬបដិសេធពាក្យសុំ នោះបទដ្ឋាននៃការបង្ហាញភស្តុតាងដែល សចស អនុវត្ត នៅពេលសម្រេចទទួលយក ឬបដិសេធមិនស្នើសុំឱ្យ អបជ ធ្វើមោឃភាពលើពាក្យសុំ មិនមានចែងក្នុងវិធានទាំងនេះទេ។ មេធាវីការពារក្តីខកខានមិនបានរៀបរាប់អំពីមូលដ្ឋានច្បាប់ដើម្បីគាំទ្រដល់សេចក្តីអះអាងរបស់ខ្លួនដែលថា ពាក្យសុំមោឃភាពគប្បីត្រូវបានវិនិច្ឆ័យដោយបទដ្ឋាននៃការបង្ហាញភស្តុតាង ដូចគ្នានឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះនៅ*តុលាការព្រហ្មទណ្ឌអន្តរជាតិចំពោះកិច្ច (មិនអចិន្ត្រៃយ៍)* ដូច្នេះដែរ។ ដូច្នេះ កសព មិនជឿជាក់ថា *បទដ្ឋាននៃភស្តុតាងបឋម* (*prima facie* test) ដូចដែលមេធាវីការពារក្តីបានលើកឡើង ពិតជាអាចអនុវត្តបានយ៉ាងច្បាស់លាស់នោះទេ។ ទោះជាយ៉ាងណាក៏ដោយ កសព ពិតជាយល់ស្របជាមួយនឹងមេធាវីការពារក្តីថា នៅក្នុងដំណាក់កាលនេះ សចស គប្បីអនុវត្តបទដ្ឋាននៃការបង្ហាញភស្តុតាងដែលទាប ជាពិសេសនៅពេលដែលអនាគតិភាពរបស់ សចស ម្នាក់ក្នុងចំណោម សចស ទាំងអស់ត្រូវបានលើកឡើងនៅក្នុងពាក្យសុំមោឃភាពនោះ[៤៦]។

១៦. វិធាន៧៦(២) នៃវិធានផ្ទៃក្នុងកំណត់ឱ្យសហចៅក្រមស៊ើបអង្កេតពិចារណាទៅលើ "សំណើសុំ" "ដើម្បីប្តឹងទៅអង្គបុរេជំនុំជម្រះ" ស្នើសុំឱ្យធ្វើមោឃភាព។ អនុវិធាននេះមិនបានកំណត់ឱ្យសហចៅក្រមស៊ើបអង្កេតពិចារណាទៅលើអង្គសេចក្តីនៃសំណើសុំ ដែលសហចៅក្រមស៊ើបអង្កេតពិតជាបានបំពេញកិច្ចនេះ និងបានលើកឡើងថា វាជាចេតនារបស់ខ្លួននៅពេលនិយាយយោងទៅលើការពិចារណាពី "អង្គសេចក្តីនៃការទាមទាររបស់មេធាវីការពារក្តីនៅក្នុងករណីនេះ"[៤៧]។ មិនមែនសហចៅក្រមស៊ើបអង្កេតទេដែលត្រូវពិចារណាទៅលើអង្គសេចក្តីនៃពាក្យសុំមោឃភាព តែនេះជាតួនាទីរបស់អង្គបុរេជំនុំជម្រះដែលមានចែងយ៉ាងច្បាស់នៅក្នុងវិធាន ៧៣(ខ) នៃវិធានផ្ទៃក្នុង។ វិធាន៧៣នៃវិធានផ្ទៃក្នុងដែលមានការជាប់ពាក់ព័ន្ធចែងថា៖

---

[៤៥] បណ្តឹងឧទ្ធរណ៍ស្តីពីសំណើសុំឱ្យធ្វើមោឃភាព កថាខណ្ឌ២៦-២៧ (ជើងទំព័រត្រូវបានលុប)។

[៤៦] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ២០។

[៤៧] ដីកាសម្រេចបដិសេធសំណើសុំឱ្យធ្វើមោឃភាពដែលរងការជំទាស់ កថាខណ្ឌ១១។

E.C.C.C. * C.E.T.C. * PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE

[...] អង្គបុរេជំនុំជម្រះមានអំណាចដាច់មុខទៅលើ៖

ក) បណ្តឹងឧទ្ធរណ៍ដែលធ្វើឡើងប្រឆាំងនឹងសេចក្តីសម្រេច និងកិច្ចស៊ើបសួររបស់សហចៅក្រមស៊ើបអង្កេត ដូចមានចែងនៅក្នុងវិធាន៧៤។

ខ) ពាក្យសុំមោឃភាពនៃកិច្ចស៊ើបសួរណាមួយ ដូចមានចែងនៅក្នុងវិធាន៧៦ និង [...][៤៨]។

១៧. គួរកត់សម្គាល់ថា កំហុសនីតិវិធីដែលត្រូវបានស្នើសុំឲ្យធ្វើមោឃភាព គឺជាផលវិបាកនៃកិច្ចស៊ើបសួរដែលដឹកនាំដោយសហចៅក្រមស៊ើបអង្កេត។ មានការចោទប្រកាន់ថា ប្រតិភូរបស់សហចៅក្រមស៊ើបអង្កេត អាចជាអ្នកស៊ើបអង្កេត ឬអ្នកផ្សេងទៀត បានប្រព្រឹត្តកំហុសនីតិវិធី ឬថា សហចៅក្រមស៊ើបអង្កេតខ្លួនឯងបានប្រព្រឹត្តខុសដោយផ្ទាល់ តាមរូបភាពណាមួយ ទាក់ទងនឹងនឹងអ្វីដែលជាកម្មវត្ថុនៃការដាក់ពាក្យសុំមោឃភាព។ ក្នុងករណីនេះ ក៏មានការចោទប្រកាន់ដែលត្រូវបានធ្វើឡើងប្រឆាំងនឹងចៅក្រមស៊ើបអង្កេតមួយរូប ក្នុងចំណោមសហចៅក្រមស៊ើបអង្កេតទាំងពីររូបដែលថាបានប្រព្រឹត្តខុស និងបានរំលោភសិទ្ធិរបស់ជនត្រូវចោទ។

១៨. បទដ្ឋាននៃការបង្ហាញភស្តុតាង ដែលត្រូវអនុវត្តដោយសហចៅក្រមស៊ើបអង្កេត នៅពេលសម្រេចថាតើត្រូវស្នើសុំ ឬមិនស្នើសុំទៅអង្គបុរេជំនុំជម្រះឲ្យធ្វើមោឃភាព តាមពាក្យសុំមោឃភាពនោះ មិនមានចែងច្បាស់លាស់នៅក្នុងវិធានផ្ទៃក្នុងទេ។ ប៉ុន្តែ អង្គបុរេជំនុំជម្រះបានបញ្ជាក់អំពីបទដ្ឋានដែលត្រូវអនុវត្តដោយសហចៅក្រមស៊ើបអង្កេត នៅក្នុងសាលដីការបស់ខ្លួនលើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ប្រឆាំងចំពោះដីកាបដិសេធពាក្យសុំមោឃភាព "សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា"[៤៩] មានន័យថា សហចៅក្រមស៊ើបអង្កេតគួរពិចារណាថាតើពាក្យសុំមានហេតុផលដែលថាមាន៖ (i) កំហុសនីតិវិធី និង (ii) "កំហុសបែបនេះវារំលោភសិទ្ធិរបស់ភាគីដែលដាក់ពាក្យសុំដែរឬក៏ទេនោះ"[៥០]។ តាមពិតទៅ សហចៅក្រមស៊ើបអង្កេតបានអនុវត្តបទដ្ឋានត្រឹមត្រូវដូច

[៤៨] វិធាន៧៣ នៃវិធានផ្ទៃក្នុង វិសោធនកម្មលើកទី៥។

[៤៩] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ប្រឆាំងចំពោះដីកាបដិសេធពាក្យសុំមោឃភាព សាលដីកាលេខ០០២/១៩-០៧-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ០៦) ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៨ ឯកសារ D55/I/8 ("សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា") កថាខណ្ឌ២២-២៣។

[៥០] វិធាន៤៨ នៃវិធានផ្ទៃក្នុង វិសោធនកម្មលើកទី៥។



PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE PRÉLIMINAIRE

ដែលបានលើកឡើងដោយអង្គបុរេជំនុំជម្រះ[៥១] ប៉ុន្តែ បានអនុវត្តបទដ្ឋានបង្ហាញភស្តុតាងមិនបានត្រឹមត្រូវ ដោយសារសហចៅក្រមស៊ើបអង្កេតគ្រាន់តែពិចារណាថាតើមានករណីជំទាស់តវ៉ាដែរ ឬអត់នោះ ហើយមិនបានពិនិត្យមើលអង្គសេចក្តីនៃពាក្យសុំនេះទេ។ នៅពេលពិចារណាទៅលើពាក្យសុំនៅក្រោមវិធាន៧៦(២) នៃវិធានផ្ទៃក្នុង សហចៅក្រមស៊ើបអង្កេតត្រូវតែជឿជាក់ថា មានពាក្យសុំដែលគាំទ្រដោយទឡ្ហីករណ៍ប្រកបដោយហេតុផល ដោយការបញ្ជាក់អះអាងថា មានកំហុសនីតិវិធី ហើយកំហុសបែបនេះរំលោភសិទ្ធិរបស់ភាគីដាក់ពាក្យសុំ។ ត្រង់ចំណុចដែលថា សហចៅក្រមស៊ើបអង្កេតត្រូវអនុវត្តបទដ្ឋានត្រឹមត្រូវ ព្រមទាំងពាក្យសុំដូចជាក្នុងករណីនេះ ដែលសំដៅលើទង្វើផ្ទាល់ខ្លួនរបស់សហចៅក្រមស៊ើបអង្កេតម្នាក់នោះ គឺមិនមានលក្ខខណ្ឌតម្រូវឱ្យចៅក្រមដែលប្រឈមមុខនឹងបញ្ហា ដកខ្លួនចេញពីការពិនិត្យមើលពាក្យសុំ ដោយសារថា ការពិនិត្យមើលបែបនេះ គឺជាទម្រង់ដែលធ្វើតែឯងបាននោះទេ ហើយការពិចារណាទៅលើអង្គសេចក្តីនៃពាក្យសុំគឺសម្រាប់តែអង្គបុរេជំនុំជម្រះតែប៉ុណ្ណោះ។

១៩. អង្គបុរេជំនុំជម្រះយល់ឃើញថា ក្នុងការអនុវត្តបទដ្ឋានត្រឹមត្រូវនៅក្នុងបញ្ហាពិសេសនេះ ដោយការប្រើប្រាស់បទដ្ឋានត្រួតពិនិត្យឱ្យបានត្រឹមត្រូវ ពាក្យសុំដែលមានបញ្ជាក់ហេតុផលដោយការលើកឡើងនូវករណីដែលអាចជជែកតវ៉ាថាមាន៖ (i) កំហុសនីតិវិធី និង(ii) "កំហុសបែបនេះរំលោភសិទ្ធិរបស់ភាគីដែលដាក់ពាក្យសុំ"[៥២]។ ដូច្នេះ មូលហេតុទីមួយនៃបណ្តឹងឧទ្ធរណ៍នេះអាចទទួលយកបាន។

២០. ជាផលវិបាកពីបញ្ហានេះ អង្គបុរេជំនុំជម្រះយល់ឃើញថា វាជាការសមស្របក្នុងការពិចារណាទៅលើបញ្ហានេះ ប្រសិនបើសហចៅក្រមស៊ើបអង្កេតបានបញ្ជូនសំណើសុំឱ្យធ្វើមោឃភាពមកឱ្យអង្គបុរេជំនុំជម្រះតាំងពីដំបូងមកនោះ។ អង្គបុរេជំនុំជម្រះមិនត្រូវពិចារណាលើបញ្ហានេះដោយសំអាងទៅលើបណ្តឹងឧទ្ធរណ៍ស្នើសុំឱ្យធ្វើមោឃភាពនោះទេ ប៉ុន្តែដោយសំអាងលើសំណើសុំឱ្យធ្វើមោឃភាព និងឯកសារគាំទ្រលើសំណើសុំនេះ។

[៥១] ដីកាសម្រេចបដិសេធសំណើសុំឱ្យធ្វើមោឃភាពដែលរងការជំទាស់ កថាខណ្ឌ១០។

[៥២] វិធាន៤៨ នៃវិធានផ្ទៃក្នុង វិសោធនកម្មលើកទី៥។

## V. ច្បាប់ដែលអាចអនុវត្តបានចំពោះនីតិវិធីធ្វើមោឃភាព នៅចំពោះមុខអង្គបុរេជំនុំជម្រះ

២១. នៅក្រោមវិធាន៤៨ នៃវិធានផ្ទៃក្នុង ដើម្បីឱ្យកិច្ចស៊ើបសួរ ឬកិច្ចរបស់អង្គជំនុំជម្រះអាចត្រូវបានចាត់ទុកជាមោឃៈ នោះជនត្រូវចោទត្រូវបង្ហាញពីអត្ថិភាពនៃកំហុសនីតិវិធីដែលបានចោទប្រកាន់ថាបណ្តាលឱ្យមានការរំលោភសិទ្ធិរបស់ខ្លួន។ អង្គបុរេជំនុំជម្រះនឹងបកស្រាយ"ការរំលោភសិទ្ធិ"[៥៣] ដូចដែលបានយោងទៅវិធាន៤៨ នៃវិធានផ្ទៃក្នុងថា "ជាការប៉ះពាល់ដល់ផលប្រយោជន៍"[៥៤]។ អង្គបុរេជំនុំជម្រះបានពិចារណាកាលពីមុនរួចមកហើយ នៅក្នុងសាលដីការបស់ខ្លួនសម្រេចទៅលើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ថា ហេតុដូច្នេះ ការរំលោភសិទ្ធិរបស់ជនត្រូវចោទនៅក្រោមកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ឬវិធានផ្ទៃក្នុង ត្រូវបានពិចារណាថាជាកំហុសនីតិវិធី ដែលបង្កឱ្យមានការប៉ះពាល់ដល់ផលប្រយោជន៍ ហើយហេតុដូច្នេះ អាចនាំឱ្យមានមោឃភាពបាន។ ជាជម្រើស ប្រសិនបើកំហុសនីតិវិធីមិនត្រូវបានចែងថាមានមោឃភាពនៅក្នុងវិធានផ្ទៃក្នុងទេ និងប្រសិនបើមិនមានការរំលោភសិទ្ធិនៅក្រោមកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយទេ នោះអ្នកដាក់ពាក្យសុំត្រូវបង្ហាញពីអត្ថិភាពនៃកំហុសនីតិវិធីដែលបានធ្វើឱ្យខូចខាតដល់ផលប្រយោជន៍របស់ពួកគេ ដើម្បីបំពេញលក្ខខណ្ឌសម្រាប់ការធ្វើមោឃភាព[៥៥]។

២២. ទាក់ទងទៅនឹងនីតិវិធីដែលមានចែងក្នុងវិធាន៧៦(២) អង្គបុរេជំនុំជម្រះបានសម្រេចកាលពីមុនរួចមកហើយ នៅក្នុងសាលដីការបស់ខ្លួនសម្រេចទៅលើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ថា ដោយសារមិនមានបទប្បញ្ញត្តិនៅក្នុងវិធានផ្ទៃក្នុងដែលចែងថា អង្គបុរេជំនុំជម្រះអាចប្រកាសមោឃភាពទៅលើកិច្ចស៊ើបសួរដោយគំនិតផ្តួចផ្តើមរបស់ខ្លួនផ្ទាល់បាន នោះអង្គបុរេជំនុំជម្រះត្រូវធ្វើតាមពាក្យសុំរបស់ភាគីដែលត្រូវបញ្ជាក់ថា ផ្នែកណាមួយនៃដំណើរការនីតិវិធីដែលត្រូវចាត់ទុកជាមោឃៈ និងផ្តល់មូលហេតុនានាសម្រាប់ការអះអាងបែបនោះ[៥៦]។

២៣. នៅក្នុងសំណើស្តីពីការស្នើសុំឱ្យធ្វើមោឃភាព សហមេធាវីការពារក្តីលើកឡើងថា កិច្ចស៊ើបសួរ

---

[៥៣] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា កថាខណ្ឌ៣៦។

[៥៤] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា កថាខណ្ឌ៣៦។

[៥៥] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា កថាខណ្ឌ៤០-៤២ (ជើងទំព័រត្រូវបានលុប)។

[៥៦] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា កថាខណ្ឌ៣៥។

ទាំងអស់ត្រូវតែចាត់ទុកជាមោឃៈ "ដោយសារវាបានរំលោភយ៉ាងច្បាស់ក្រឡែត និងជដែលៗ ទៅលើវិធានផ្ទៃក្នុង និងបទបញ្ញត្តិដទៃទៀតដែលគ្របដណ្តប់លើដំណើរការនីតិវិធីនៅ អវតក និងបានធ្វើឱ្យប៉ះពាល់ដល់សិទ្ធិរបស់ជនត្រូវចោទ ក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌"[៥៧]។ ហេតុដូច្នេះ អ្នកដាក់ពាក្យសុំស្នើឱ្យធ្វើមោឃភាពកិច្ចស៊ើបសួរទាំងមូល មិនមែនតែ"ផ្នែកណាមួយ" នៃដំណើរការនីតិវិធីនោះទេ[៥៨]។

២៤. អង្គបុរេជំនុំជម្រះយល់ឃើញថា នីតិវិធីធ្វើមោឃភាពដូចបានអនុវត្តនៅក្នុងសាលដីកាសម្រេចទៅលើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា "គឺមិនមែនតាក់តែងដើម្បីធ្វើមោឃភាពកិច្ចស៊ើបសួរជាទូទៅនោះទេ [...] ប៉ុន្តែ ត្រូវបានរៀបរៀងឡើងដើម្បីធ្វើមោឃភាពផ្នែកទាំងឡាយណានៃដំណើរការនីតិវិធីដែលធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ជនត្រូវចោទ ដែលត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់[៥៩]។ ហេតុដូច្នេះ ការអនុវត្តការធ្វើមោឃភាពត្រូវតែបញ្ជាក់ហេតុផលឱ្យបានជាក់លាក់ថា តើកិច្ចស៊ើបសួរ ឬកិច្ចរបស់អង្គជំនុំជម្រះណាមួយដែលមានកំហុសនីតិវិធី និងនៅពេលណាដែលអាចអនុវត្តបាន បញ្ជាក់អះអាងពីផលប្រយោជន៍ដែលត្រូវបានប៉ះពាល់។ នៅក្នុងស្ថានភាពចុងក្រោយនេះ ប្រសិនបើការធ្វើមោឃភាពរាល់កិច្ចស៊ើបសួរ ឬកិច្ចរបស់អង្គជំនុំជម្រះត្រូវបានស្នើឡើង នោះអ្នកដាក់ពាក្យសុំត្រូវបង្ហាញពីអត្ថិភាពនៃកំហុសនីតិវិធីដែលបានធ្វើឱ្យខូចខាតដល់ផលប្រយោជន៍របស់ខ្លួន នៅក្នុងករណីនេះទាំងមូល។ នៅពេលដែលការរំលោភសិទ្ធិរបស់ជនត្រូវចោទនៅក្រោមកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ឬវិធានផ្ទៃក្នុងត្រូវបានបង្ហាញឡើង កំហុសនីតិវិធីបង្កការប៉ះពាល់ដល់ផលប្រយោជន៍ នឹងនាំឱ្យឈានដល់ការធ្វើមោឃភាពកិច្ចស៊ើបសួរ ឬកិច្ចរបស់អង្គជំនុំជម្រះជាក់លាក់ បើទោះបីជាអង្គបុរេជំនុំជម្រះមានឆន្ទានុសិទ្ធិលើកឡើងពីផលវិបាកនៃការធ្វើមោឃភាពទៅលើករណីនេះទាំងស្រុងក៏ដោយ។

២៥. វាជាការពិតហើយ ដែលអង្គបុរេជំនុំជម្រះអាចលើកឡើងពីផលវិបាកនៃការធ្វើមោឃភាពស្តីពីកំហុសនីតិវិធីជាក់លាក់ទៅលើករណីនេះទាំងមូល ដោយអនុលោមតាមវិធាន៧៦(៥) នៃវិធានផ្ទៃ

---

[៥៧] សំណើសុំឱ្យធ្វើមោឃភាពកិច្ចស៊ើបសួរ កថាខណ្ឌ៥១។

[៥៨] សំណើសុំឱ្យធ្វើមោឃភាពកិច្ចស៊ើបសួរ កថាខណ្ឌ៥៩។

[៥៩] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំធ្វើមោឃភាពដោយមូលហេតុនៃនីតិវិធី ចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១០ សាលដីកាលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ក.ច (អ.ប.ជ៣០) ឯកសារ D197/5/8 ("សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន") កថាខណ្ឌ២៤ (ជើងទំព័រត្រូវបានលុប)។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C.

ក្នុងដែលចែងថា៖

"នៅពេលដែលអង្គបុរេជំនុំជម្រះសម្រេចទុកជាមោឃៈកិច្ចស៊ើបសួរណាមួយ នោះអង្គបុរេជំនុំជម្រះត្រូវសម្រេចថាតើមោឃភាពនោះមានប៉ះពាល់ដល់កិច្ច ឬដីកាដទៃទៀតដែរឬក៏ទេនោះ"[៦០]។

២៦. អង្គបុរេជំនុំជម្រះកត់សំគាល់ឃើញថា ក្នុងករណីដែលភាគីស្នើសុំឱ្យធ្វើមោឃភាពផ្នែកសំខាន់មួយ ឬច្រើននៃដំណើរការនីតិវិធី នោះក្នុងករណីជាក់ស្តែង សំណើនេះអាចនាំឱ្យកិច្ចស៊ើបសួរទាំងអស់ដែលពាក់ព័ន្ធនឹងផលប្រយោជន៍ដែលរងការអន្តរាយនោះ ត្រូវចាត់ទុកជាមោឃៈ។ ជាពិសេសកាលណាផលប្រយោជន៍ដែលរងការអន្តរាយនោះប៉ះពាល់ខ្លាំងដល់ដំណើរការនីតិវិធី ឬកិច្ចស៊ើបសួរ ឬការស៊ើបអង្កេតផ្សេងទៀត ការចាត់ទុក"ផ្នែកណាមួយនៃដំណើរការនីតិវិធី" ជាមោឃៈអាចមានផលវិបាកទៅលើដំណើរការនីតិវិធីទាំងមូល។ អង្គបុរេជំនុំជម្រះនឹងធ្វើការសម្រេចជួសជុលបញ្ហាបែបនោះ តាមមូលដ្ឋានករណីនីមួយៗ បន្ទាប់ពីមានភស្តុតាងបញ្ជាក់ថា មានកំហុសនីតិវិធី។

២៧. អង្គបុរេជំនុំជម្រះកត់សំគាល់ឃើញថា នៅពេលដែលសម្រេចមោឃភាពតាមសំណើកិច្ចស៊ើបសួរ ឬការស៊ើបអង្កេតនានាដែលត្រូវបានចាត់ទុកជាមោឃៈនិងទុកជាឥតបានការ នឹងត្រូវបានដកចេញពីឯកសារក្នុងសំណុំរឿង។ ក្នុងករណីនេះ ប្រសិនបើកិច្ចស៊ើបសួរទាំងមូលត្រូវបានចាត់ទុកជាមោឃៈ ឯកសារ/សម្ភារៈទាំងអស់នឹងត្រូវបានដកចេញពីសំណុំរឿង ដែលនាំឱ្យមានផលវិបាកមួយដែលត្រូវតែញែកឱ្យដាច់ពីការផ្អាកដំណើរការនីតិវិធីដោយសារការបំពាននីតិវិធី។ នីតិវិធីទាំងពីរនេះអនុវត្តបទដ្ឋានខុសៗគ្នា ហើយនាំមកនូវផលវិបាកខុសគ្នាផងដែរ។ ប្រសិនបើមោឃភាពត្រូវបានបង្គាប់នោះ ទោះក្នុងកិច្ចស៊ើបសួរទាំងមូល នោះគ្មានអ្វីអាចរារាំងមិនឱ្យកិច្ចស៊ើបសួរថ្មី ដើម្បីដាក់សម្ភារៈ/ឯកសារថ្មីដែលមិនប្រឡាក់ប្រឡូសនឹងកំហុសឆ្គងនេះ ចូលក្នុងសំណុំរឿងបានទេ។ ក្នុងករណីផ្អាកដំណើរការនីតិវិធី ដំណើរការនីតិវិធីទាំងមូលនឹងត្រូវបញ្ឈប់ ពីព្រោះការបំពាននោះត្រូវបានចាត់ទុកថាការបំពានធ្ងន់ធ្ងរជាក់ស្តែង ដែលធ្វើឱ្យអន្តរាយដល់សុចរិតភាពនៃដំណើរការទាំងមូល ពេលនោះនឹងលែងមានករណីណាមួយត្រូវយកមកដោះស្រាយតទៅទៀតហើយ។

[៦០] វិធាន៧៦(៥) នៃវិធានផ្ទៃក្នុង វិសោធនកម្មលើកទី៥។

## VI. ការពិចារណាពីមូលដ្ឋាននៃការស្នើសុំឲ្យធ្វើមោឃភាព

២៨. អង្គបុរេជំនុំជម្រះកត់សំគាល់ឃើញថា សំណើសុំឲ្យធ្វើមោឃភាពបញ្ជាក់ពីមូលហេតុចំនួនបួន ដែលបានស្នើសុំមោឃភាពដោយសារមូលហេតុកំហុសនីតិវិធី ដែលក្នុងនោះរួមមានទាំងការចោទប្រកាន់ពីភាពលំអៀងផងដែរ។

### ក. ការខ្វះភាពអនាគតិ

២៩. សហមេធាវីការពារក្តីបានផ្អែកតែលើសេចក្តីថ្លែងការណ៍របស់លោក Wayne Bastin ចុះថ្ងៃទី៨ ខែតុលា ឆ្នាំ២០០៩ (សេចក្តីថ្លែងការណ៍ទី១របស់ Bastin)[៦១] ធ្វើជាមូលដ្ឋាននៃសំណើរបស់ខ្លួន។ សហមេធាវីការពារក្តីបានតវ៉ាថា យោបល់របស់ចៅក្រម Marcel LEMONDE បង្ហាញច្បាស់ពីការពេញចិត្តលើភស្តុតាងដាក់បន្ទុកជាងភស្តុតាងដោះបន្ទុក ហើយបង្ហាញពីវិធីសាស្ត្រមួយដែលលំអៀង និងគ្មានអនាគតិ[៦២]។ សំណើសុំឲ្យធ្វើមោឃភាពបានកត់សំគាល់ថា នៅក្នុងចម្លើយតបរួមរបស់ចៅក្រម Marcel LEMONDE[៦៣] មិនមានភស្តុតាងជាសំអាងដើម្បីបដិសេធអង្គហេតុដែលថាខ្លួនមិនបាននិយាយបែបនេះនោះទេ[៦៤] ផ្ទុយទៅវិញចៅក្រម Marcel LEMONDE បញ្ជាក់ថា "បើគាត់បាននិយាយ ការថ្លែងបែបនោះ គ្រាន់តែការនិយាយលេងប៉ុណ្ណោះ ហើយអ្នកដែលវត្តមាននៅទីនោះក៏បានយល់បែបនេះដែរ"[៦៥]។ សហមេធាវីការពារក្តីបានតវ៉ាថា បុគ្គលិកមួយចំនួននៃ កសចស បានសំដែងប្រតិកម្មថាពួកគេមិនចាត់ទុកយោបល់នោះជាការនិយាយកំប្លែងទេ[៦៦]។ ពួកគេបានបញ្ជាក់បន្ថែមថា យោបល់បែបនេះមិនសមស្របទេ កាលណាយោបល់នេះចេញពីបុគ្គលដែលមានតំណែងដូចចៅក្រម

---

[៦១] សេចក្តីថ្លែងលើកទី១ របស់ Bastin ចុះថ្ងៃទី៨ ខែតុលា ឆ្នាំ២០០៩ ឯកសារ D263.3 -វត្ថុតាង១ ភ្ជាប់ជាមួយសំណើសុំឲ្យធ្វើមោឃភាពកិច្ចស៊ើបសួរ។

[៦២] សំណើសុំឲ្យធ្វើមោឃភាពកិច្ចស៊ើបសួរ កថាខណ្ឌ១៣-១៤។

[៦៣] ចម្លើយតបរួមរបស់សហចៅក្រមស៊ើបអង្កេត Marcel Lemonde ទៅនឹងបណ្តឹងជំទាស់ដែលត្រូវបានធ្វើក្នុងនាម អៀង សារី និង ខៀវ សំផន ចុះថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០០៩ ឯកសារ D263.5 -- វត្ថុតាង៣ ភ្ជាប់ជាមួយសំណើសុំឲ្យធ្វើមោឃភាពកិច្ចស៊ើបសួរ។ ("ចម្លើយតបរួម")។

[៦៤] សំណើសុំឲ្យធ្វើមោឃភាពកិច្ចស៊ើបសួរ កថាខណ្ឌ១៤។

[៦៥] សំណើសុំឲ្យធ្វើមោឃភាពកិច្ចស៊ើបសួរ កថាខណ្ឌ១២។

[៦៦] សំណើសុំឲ្យធ្វើមោឃភាពកិច្ចស៊ើបសួរ កថាខណ្ឌ១៥។

Marcel LEMONDE ពីព្រោះយោបល់នេះបង្ហាញពីគោលជំហរលំអៀងក្នុងការដឹកនាំបុគ្គលិក កសចស ហើយវាប្រឆាំងនឹងផលប្រយោជន៍ជនត្រូវចោទដែលមានសិទ្ធិទទួលបានកិច្ចស៊ើបសួរ ដែល "ស្វែងរកភស្តុតាងដោះបន្ទុកស្មើភាពគ្នាដោយអនាគតិ" [៦៧]។

៣០. សហមេធាវីការពារក្តីប្រើការសាកល្បងរបស់ "អ្នកសង្កេតការណ៍ឥតលំអៀង" ហើយអះអាងថា អ្នកសង្កេតការណ៍នោះនឹងចាត់ទុកយោបល់នេះជា "សំដីតំណាងឲ្យការថ្លែងដោយដឹងជាមុន" ដែល អ្នកសង្កេតការណ៍ឥតលំអៀងយល់ថា "ជាវិធីសាស្ត្រស្វែងភស្តុតាងរើសអើងដែលគ្មានមនសិការ" [៦៨]។ សហមេធាវីការពារក្តីបានលើកឡើងថា ដោយសារតែមានភាពលំអៀងក្នុងកិច្ចស៊ើបសួរ ចៅក្រម Marcel LEMONDE ក៏ដូចជា កសចស បានបំពានលើវិធាន ៥៥(៥) នៃវិធានផ្ទៃក្នុង មាត្រា ១៣ នៃកិច្ចព្រមព្រៀង មាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា ២៥ នៃច្បាប់បង្កើត អ.វ.ត.ក និងមាត្រា ២, ៧ និង ៨ នៃក្រមសីលធម៌ចៅក្រមនៃ អ.វ.ត.ក ព្រមទាំងមាត្រា ៧ និង ៨ នៃក្រមសីលធម៌ចៅក្រមកម្ពុជា [៦៩]។

៣១. អង្គបុរេជំនុំជម្រះបានកំណត់ពីមុនរួមមកហើយថា ការអនុវត្តវិធានផ្ទៃក្នុងនិងយុត្តិសាស្ត្រអន្តរជាតិក្នុងបរិបទវិធាន៣៤ នៃវិធានផ្ទៃក្នុង [៧០] គឺជាបទដ្ឋានសមស្របដែលត្រូវយកមកអនុវត្តចំពោះករណីមានភាពលំអៀង។ អង្គបុរេជំនុំជម្រះបានសម្រេចថា កាលណាម្ចាស់បណ្តឹងឧទ្ធរណ៍តវ៉ាពីភាពលំអៀង ម្ចាស់បណ្តឹងឧទ្ធរណ៍មានបន្ទុកបង្ហាញភស្តុតាង ដែលមានប្រៀបលើសេចក្តីសន្និដ្ឋានពីភាពអនាគតិរបស់ចៅក្រម៖

> "ការសន្មតនេះកើតចេញពីការធ្វើសច្ចាប្រណិធានចូលកាន់តំណែងរបស់ចៅក្រម និងលក្ខណៈសម្បត្តិគ្រប់គ្រាន់របស់គាត់ [...] និងដាក់បន្ទុកដ៏ធ្ងន់ចំពោះភាគីដែលធ្វើបណ្តឹងផិតចិត្តក្នុងការដកចេញនូវការសន្មតទុកជាមុននេះ។

---

[៦៧] សំណើសុំឲ្យធ្វើមោឃភាពកិច្ចស៊ើបសួរ កថាខណ្ឌ១៦។

[៦៨] សំណើសុំឲ្យធ្វើមោឃភាពកិច្ចស៊ើបសួរ កថាខណ្ឌ១៧។

[៦៩] សំណើសុំឲ្យធ្វើមោឃភាពកិច្ចស៊ើបសួរ កថាខណ្ឌ១៩។

[៧០] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Frundzija* សំណុំរឿងលេខ IT-95-17/1-A "សាលដីកា" អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០០ កថាខណ្ឌ១៨៩ ដូចដែលបានដកស្រង់ក្នុងសេចក្តីសម្រេចស្តីពីបណ្តឹងផិតចិត្តជាបន្ទាន់របស់សហមេធាវីជនត្រូវចោទ នួន ជា ប្រឆាំងលោកចៅក្រម ន័យ ធុល ចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០០៨ សាលដីកា០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស(អ.ប.ជ០១) កថាខណ្ឌ ២០ ("សាលដីការឿងក្តី ន័យ ធុល")។



E.C.C.C * C.E.T.C * PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

[...]

ក្នុងបញ្ហានេះ អ្នកប្តឹងជិតចិត្តត្រូវបង្ហាញភស្តុតាងឲ្យបានគ្រប់គ្រាន់ដល់អង្គបុរេជំនុំជម្រះ ដើម្បីឲ្យអង្គបុរេជំនុំជម្រះយល់ឃើញថា ចៅក្រមដែលត្រូវបានចោទប្រកាន់នោះអាចមានភាពលំអៀងប្រាកដមែន។ មានចំណុចជាមូលដ្ឋានជាច្រើនដែលត្រូវបំពេញ ដើម្បីជំទាស់ទៅនឹងការសន្មតជាមុននៃភាពអនាគតិ"[៧១]។

៣២. ទោះបីជាសេចក្តីសម្រេចពីមុនរបស់អង្គបុរេជំនុំជម្រះ ឆ្លើយតបជាក់លាក់ចំពោះតែបណ្តឹងជិតចិត្តក៏ដោយ ក៏អង្គបុរេជំនុំជម្រះយល់ឃើញថា អាចយកបទដ្ឋាននោះមកអនុវត្តបានដូចគ្នា កាលណាម្ចាស់បណ្តឹងបានចោទប្រកាន់ពីភាពលំអៀងជាមូលដ្ឋាននៃបណ្តឹងតាមវិធាន ៧៦(២) នៃវិធានផ្ទៃក្នុង។ តាមវិធាននេះ អ្នកប្តឹងមានបន្ទុកបង្ហាញភស្តុតាងថា មានកំហុសនីតិវិធី ហើយកំហុសនោះជាការលំអៀងជាក់ស្តែង (ឬតាមសត្យានុម័ត) ឬជាការលំអៀងដោយចេតនា (ឬដោយអត្តនោមតិ)។ ក្នុងករណីនេះ ម្ចាស់បណ្តឹងបានតវ៉ាថា ភាពគ្មានអនាគតិ (ដូចជាភាពលំអៀង) គឺជាកំហុសនីតិវិធី ហេតុដូច្នេះម្ចាស់ត្រូវតែបង្ហាញភស្តុតាងឲ្យបានគ្រប់គ្រាន់ ដើម្បីបដិសេធការសន្មតជាមុននៃភាពអនាគតិរបស់ចៅក្រម Lemonde។ ក្នុងបរិបទនេះ បើមានភស្តុតាងបញ្ជាក់ពីភាពលំអៀងដែលបានចោទប្រកាន់នោះ ទើបអាចនាំឲ្យមានកំហុសនីតិវិធី ហើយអង្គបុរេជំនុំជម្រះនឹងត្រូវពិនិត្យមើលថាតើកិច្ចស៊ើបសួរ ឬការស៊ើបអង្កេតណាខ្លះដែលពាក់ព័ន្ធនឹងបណ្តឹងពីភាពអនាគតិ និងថាតើអ្វីខ្លះជាផលវិបាកនៃកំហុសនីតិវិធី ឧទាហរណ៍ ភាពលំអៀង ក្នុងករណីទូទៅ អង្គបុរេជំនុំជម្រះយល់ឃើញថាកិច្ចស៊ើបសួរដែលធ្វើឡើងដោយ កសចស គឺមានការឯកភាពពីសហចៅក្រមជាតិ លើកលែងតែមានភស្តុតាងបញ្ជាក់ផ្ទុយពីនេះ។

៣៣. អង្គបុរេជំនុំជម្រះបានពិចារណាការចោទប្រកាន់ជាក់លាក់ដែលបញ្ជាក់ក្នុងមូលហេតុបណ្តឹងនេះ ហើយបានកំណត់ថាភស្តុតាងដែលបានផ្តល់សម្រាប់គាំទ្រចំណុចនេះ គឺមិនគ្រប់គ្រាន់ ដូចបានបញ្ជាក់ក្នុងសេចក្តីសម្រេចរបស់ខ្លួនលើបណ្តឹងជិតចិត្តរបស់ អៀង សារី[៧២] និងសេចក្តីសម្រេចលើបណ្តឹងជិតចិត្តរបស់ ខៀវ សំផន[៧៣]។ ការចោទប្រកាន់ក្នុងបណ្តឹងនេះ គឺជាការចោទប្រកាន់ដដែលដូចគ្នានឹងការចោទ

---

[៧១] សាលដីការឿងក្តីលោក ន័យ ធុល កថាខណ្ឌ១៥ និង ១៩ (ជើងទំព័រត្រូវបានលុប)។

[៧២] សាលដីកាលើបណ្តឹងជិតចិត្តរបស់ជនត្រូវចោទ អៀង សារី ប្រឆាំងនឹងសហចៅក្រមស៊ើបអង្កេត Marcel Lemonde ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០០៩ សំណុំរឿងលេខ ០០២/០៩-១០-២០០៩-អ.វ.ត.ក/អ.ប.ជ (០១) ឯកសារលេខ ៧។

[៧៣] សាលដីកាលើបណ្តឹងជិតចិត្តរបស់ ខៀវ សំផន ប្រឆាំងនឹងសហចៅក្រមស៊ើបអង្កេត Marcel Lemonde ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ សំណុំរឿងលេខ ០០២/១៣-១០-២០០៩-អ.វ.ត.ក/អ.ប.ជ(០២) ឯកសារលេខ៧។

PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE PRELIMINAIRE

ប្រកាន់ក្នុងបណ្តឹងទាំងពីរនោះ និងផ្អែកលើសេចក្តីថ្លែងការណ៍ដដែលរបស់លោក Bastin នេះដែរ។ ម្ចាស់បណ្តឹងមិនបានលើកបញ្ហាថ្មីនៅក្នុងមូលហេតុបណ្តឹងរបស់ខ្លួនទេ ដូច្នេះអង្គបុរេជំនុំជម្រះនឹងមិនលើកយកបញ្ហាដែលខ្លួនបានសម្រេចរួចហើយមកពិចារណាឡើងវិញទេ លើកលែងតែមានភស្តុតាងថ្មីគ្រប់គ្រាន់ និងមានឧត្តមានុភាពលើការសន្និដ្ឋានជាមុននៃអនាគតិភាពរបស់ចៅក្រម Lemonde។

៣៤. អង្គបុរេជំនុំជម្រះកត់សំគាល់ឃើញថា សហមេធាវីការពារក្តីបានភ្ជាប់ឯកសារបញ្ជាក់អត្តសញ្ញាណរបស់លោក Bastin និងអង្គហេតុបញ្ជាក់ថា គាត់ជាអ្នកសរសេរសេចក្តីថ្លែងការណ៍នោះ រួមទាំងសេចក្តីប្រកាសកំណត់ដៃសង្ខេបកន្លះទំព័ររបស់លោក Bastin ដែលកត់ត្រាក្នុងកិច្ចប្រជុំក្នុងខែសីហា ឆ្នាំ២០០៩ និង សេចក្តីពន្យល់ពីកំណត់ដៃសង្ខេបដោយលោក Bastin ជាឧបសម្ព័ន្ធនៃបណ្តឹងឧទ្ធរណ៍នេះ។ ដូចបានសម្រេចក្នុងកថាខណ្ឌ ១៩ ខាងលើ អង្គបុរេជំនុំជម្រះមិនពិចារណាឯកសារទាំងនេះទេ ដោយសារអង្គបុរេជំនុំជម្រះបានទទួលបញ្ហានេះក្នុងរូបភាពជាមូលដ្ឋាននៃសំណើសុំឱ្យធ្វើមោឃភាព មិនមែនជាមូលហេតុបណ្តឹងឧទ្ធរណ៍ទេ។ ប្រសិនបើអង្គបុរេជំនុំជម្រះបានទទួលបញ្ហានេះជាមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍ អង្គបុរេជំនុំជម្រះបានសម្រេចក្នុងសេចក្តីសម្រេចមួយលើបណ្តឹងជិតចិត្តចៅក្រម Lemonde ថា ភស្តុតាងបន្ថែមនេះ "មិនបានផ្តល់មូលដ្ឋានអង្គហេតុបន្ថែម ដែលមានឧត្តមានុភាពលើភាពអនាគតិរបស់ចៅក្រម Lemonde ឡើយ"[៧៤]។

៣៥. ដោយសារមិនមានភស្តុតាងបញ្ជាក់ថា កំហុសនីតិវិធីកើតឡើងពីភាពលំអៀង ហេតុដូច្នេះ អង្គបុរេជំនុំជម្រះនឹងមិនពិចារណាបញ្ហានេះតទៅទៀតទេ។

## ខ. <u>ការបំពានលើការបែងចែកអំណាចរវាងការិយាល័យសហព្រះរាជអាជ្ញា និង កសចស និងការគ្មានឯករាជ្យភាព</u>

៣៦. នៅថ្ងៃទី២ ខែធ្នូ ឆ្នាំ២០០៩ លោក Bastin បានផ្តល់សេចក្តីថ្លែងការណ៍មួយទៀត ជូនសហមេធាវី

---

[៧៤] សាលដីកាលើបណ្តឹងជិតចិត្តរបស់លោក អៀង សារី និង លោកស្រី អៀង ធីរិទ្ធ តាមវិធាន ៣៤ នៃវិធានផ្ទៃក្នុង ប្រឆាំងនឹងចៅក្រម Marcel Lemonde ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១០ ឯកសារលេខ: -8-, សំណុំរឿងលេខ ០០២/០៧-១២-២០០៩-អ.វ.ត.ក/(អ.ប.ជ០៥)។ ឯកសារលេខ: -6-, សំណុំរឿងលេខ ០០២/១១-១២-២០០៩-អ.វ.ត.ក/(អ.ប.ជ០៧) កថាខណ្ឌ៤១ ("សាលដីកាលើបណ្តឹងជិតចិត្តរបស់ អៀង សារី និង អៀង ធីរិទ្ធ")។

ការពារក្តី (“សេចក្តីថ្លែងការណ៍ទី២ របស់ Bastin”)[៧៥] ដែលបាននិយាយរំលឹកជាពិសេស អំពីកិច្ចប្រជុំរបស់ កសចស ដែលធ្វើឡើងក្នុងខែវិច្ឆិកា ឬខែធ្នូ ឆ្នាំ២០០៨ ដែលក្នុងកិច្ចប្រជុំនោះ គេបានចែកឯកសារជូនអ្នកដែលវត្តមានក្នុងកិច្ចប្រជុំ រួមទាំងចៅក្រម Lemonde ផងដែរ។ តាមសំដីរបស់ Bastin បុគ្គលិក កសចស ដែលចែកឯកសារនោះបានពន្យល់ថាបុគ្គលិកការិយាល័យសហព្រះរាជអាជ្ញា (“កសព”) បានផ្តល់ឯកសារនេះដោយផ្ទាល់។ លោក Bastin បានពន្យល់ថា ឯកសារនោះ ជាឯកសារក្រៅផ្លូវការ ហើយភាគច្រើននៃអ្នកចូលរួមបានទទួលឯកសារនោះ[៧៦]។

៣៧. សហមេធាវីការពារក្តីបានលើកឡើងថា ការទទួលឯកសារនេះបង្កើតបានជាឥរិយាបទមួយរំលោភដោយផ្ទាល់ទៅលើ “ករណីយកិច្ចទូទៅដែលត្រូវបំពេញភារកិច្ចដោយឯករាជ្យ” ដូចមានចែងក្នុងមាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និង “ករណីយកិច្ចជាក់លាក់ដោយមិនប្រាស្រ័យទាក់ទងជាមួយភាគីណាមួយក្នុងពេលដំណើរការនីតិវិធីដោយគ្មានវត្តមានភាគីមួយផ្សេងទៀត” ដូចមានចែងក្នុងមាត្រា ៩ នៃក្រមសីលធម៌ចៅក្រមកម្ពុជា[៧៧]។ លើសពីនេះទៅទៀត សហមេធាវីការពារក្តីបានលើកឡើងថា កសចស បានបំពានលើកាតព្វកិច្ចធានាការបែងចែកអំណាចរវាងស្ថាប័នអយ្យការនិងអំណាចតុលាការ ដែលបានចែងក្នុងវិធាន ២១ នៃវិធានផ្ទៃក្នុង ដោយសារការប្រើឯកសារក្រៅផ្លូវការដែល កសព បានផ្តល់ជូន[៧៨]។

៣៨. បន្ទាប់មក សហមេធាវីការពារក្តីបានផ្អែកលើ “ស្មារតីនៃវិធាន ៥០, ៥៣ និងវិធាន ៥៥ នៃវិធានផ្ទៃក្នុង”[៧៩] ហើយអះអាងថា “មិនគប្បីមានទំនាក់ទំនងក្រៅផ្លូវដោយផ្ទាល់” រវាង កសព និង កសចស ហើយ “ក្រៅពីឯកសារក្នុងសំណុំរឿង ស្ថាប័នទាំងពីរនេះមិនត្រូវបញ្ជូនឯកសារផ្សេងទៅវិញទៅមកនោះឡើយ”[៨០]។ សហមេធាវីការពារក្តីទទួលស្គាល់ថា ទាំងវិធានផ្ទៃក្នុងនិងច្បាប់គ្រប់គ្រង អ.វ.ត.ក មិនបានចែងពីមូលដ្ឋាននៃការតវ៉ានេះទេ ប៉ុន្តែសហមេធាវីការពារក្តីបញ្ជាក់ថាអំពើបែបនេះត្រូវបាន

---

[៧៥] សេចក្តីថ្លែងការណ៍ទី២ របស់ Bastin ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០០៩ ឯកសារ D263.4 --វត្ថុតាង២ ភ្ជាប់ជាមួយសំណើសុំឲ្យធ្វើមោឃភាពកិច្ចស៊ើបសួរ។

[៧៦] សេចក្តីថ្លែងការណ៍ទី២ របស់ Bastin ទំព័រ៣។

[៧៧] សំណើសុំឲ្យធ្វើមោឃភាពកិច្ចស៊ើបសួរ កថាខណ្ឌ២៤។

[៧៨] សំណើសុំឲ្យធ្វើមោឃភាពកិច្ចស៊ើបសួរ កថាខណ្ឌ២៥។

[៧៩] សេចក្តីថ្លែងការណ៍ទី២ របស់ Bastin ទំព័រ២៨។

[៨០] សំណើសុំឲ្យធ្វើមោឃភាពកិច្ចស៊ើបសួរ កថាខណ្ឌ២៩។

00541197



ហាមដោយបទប្បញ្ញត្តិស្ដីពីអនាគតិភាព និងឯករាជ្យភាព[៨១]។

៣៩. អង្គបុរេជំនុំជម្រះពិចារណាថា ការចោទប្រកាន់នៅក្នុងមូលហេតុនៃសំណើរនេះ គឺជាការចោទប្រកាន់ថា កសចស បានបំពានកាតព្វកិច្ចរបស់ខ្លួនក្នុងការបំពេញការងារដោយឯករាជ្យ ជាពិសេស អនុលោមតាមវិធាន ២១ និងវិធាន ៥៥(២) នៃវិធានផ្ទៃក្នុង។ លុះត្រាតែមានភស្តុតាងបញ្ជាក់ច្បាស់ ទើបអំពើនោះអាចបង្កើតបានជាកំហុសនីតិវិធី ដែលបង្កើតបានជាការបំពានលើសិទ្ធិរបស់ភាគី។

៤០. អង្គបុរេជំនុំជម្រះកត់សំគាល់ឃើញថា សេចក្ដីថ្លែងការណ៍ទី២ របស់ Bastin គឺជាភស្តុតាងតែមួយគត់ដែលសហមេធាវីការពារក្ដីបានយកមកធ្វើជាមូលដ្ឋានគាំទ្រសំណើរសុំឲ្យធ្វើមោឃភាព។ សហមេធាវីការពារក្ដីមិនបានទាក់ទងជាមួយបុគ្គលដែលខ្លួនអះអាងថា បានវត្តមានក្នុងកិច្ចប្រជុំនោះ ឬបានពាក់ព័ន្ធនឹងហេតុការណ៍នោះដោយផ្ទាល់ ឬដោយប្រយោល ដើម្បីឲ្យផ្ដល់ភស្តុតាងឡើយ។ សេចក្ដីថ្លែងការណ៍នោះ មានព័ត៌មានផ្ទុយគ្នាទាក់ទងបុគ្គលិកដែលពិតជាបានទទួលឯកសារក្នុងកិច្ចប្រជុំនោះ ដោយបញ្ជាក់ក្នុងកថាខណ្ឌតែមួយថា "សមាជិកទាំងអស់ដែលវត្តមាន" និង "ភាគច្រើននៃអ្នកចូលរួម" បានទទួលឯកសារនោះ[៨២]។ ក្នុងខណៈដែលលោក Bastin បានចោទប្រកាន់ថា ឯកសារនេះ "ទាក់ទងនឹងទីកន្លែងនៃកិច្ចស៊ើបសួរ" និងនិយាយថា "គាត់បានត្រឡប់មកកាន់ការិយាល័យរបស់គាត់វិញ និងបានអានឯកសារនោះ ឯកសារពិតប្រាកដមិនត្រូវបានផ្ដល់ជូនទេ ហើយខ្លឹមសារនៃឯកសារនោះក៏មិនបានបំភ្លឺនៅពេលក្រោយមកទៀតដែរ[៨៣]។

៤១. អង្គបុរេជំនុំជម្រះយល់ឃើញថា កាចោទប្រកាន់ក្នុងសេចក្ដីថ្លែងការណ៍ទី២ របស់ Bastin គឺគ្រាន់តែជាអំណះអំណាងតែប៉ុណ្ណោះ ហើយសហមេធាវីមិនបានបង្ហាញភស្តុតាងគ្រប់គ្រាន់ដើម្បីបញ្ជាក់ថា មានកំហុសនីតិវិធីឡើយ។ ហេតុដូច្នេះ អង្គបុរេជំនុំជម្រះបដិសេធចោលមូលហេតុទីពីរនៃសំណើសុំឲ្យធ្វើមោឃភាព។

## គ. <u>"ភាគីអន្តរជាតិ" បានលាក់បំបាំងព័ត៌មានពី "ភាគីជាតិ"</u>

៤២. សហមេធាវីការពារក្ដីបានផ្អែកលើសេចក្ដីថ្លែងការណ៍ទី២ របស់ Bastin ដើម្បីផ្ដល់ "ឧទាហរណ៍ជា

---

[៨១] សំណើសុំឲ្យធ្វើមោឃភាពកិច្ចស៊ើបសួរ កថាខណ្ឌ២៩។

[៨២] សេចក្ដីថ្លែងការណ៍ទី២ របស់ Bastin ទំព័រ៣។

[៨៣] សេចក្ដីថ្លែងការណ៍ទី២ របស់ Bastin ទំព័រ៤។

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

ច្រើនដែលបញ្ជាក់ថា សហចៅក្រមអន្តរជាតិ និងបុគ្គលិក កសចស បានលាក់កំបាំងព័ត៌មានពីសមភាគីជាតិ”។ ម្ចាស់បណ្តឹងបានផ្តល់ឧទាហរណ៍មួយចំនួនដូចខាងក្រោមនេះ៖

១- ពាក់ព័ន្ធនឹងឯកសារដែលនិយាយដល់នោះត្រូវបានគេផ្តល់ឲ្យទៅ កសចស ពី កសព “វាត្រូវបានគេបញ្ជាក់ជាច្រើនសារថា ឯកសារនេះសំខាន់ណាស់ ហើយមិនត្រូវចែករំលែកដល់បុគ្គលិកជនជាតិកម្ពុជានោះទេ”។

២- ចៅក្រម យូ ប៊ុនឡេង មិនបានឯកភាពឲ្យក្រុមថតខ្សែភាពយន្តអមដំណើរអ្នកស៊ើបអង្កេត ដែលចៅក្រមរូបនេះបានដឹងក្រោយពីរឿងនេះបានកើតឡើងរួចទៅហើយ ដោយសារចៅក្រម Lemonde មិនបានពិភាក្សាបញ្ហានេះជាមួយគាត់។ និង

៣- ចេតនារបស់ចៅក្រម Lemonde គឺថាបុគ្គលិកជាតិមិនអាចមើលប្រព័ន្ធទិន្នន័យ (database) សាក្សីផ្ទៃក្នុងបានទេ[៨៤]។

សហមេធាវីការពារក្តីបានលើកឡើងថា ឧប្បត្តិហេតុទាំងអស់នេះ “បង្ហាញឲ្យឃើញថា បុគ្គលិកអន្តរជាតិរបស់ កសចស ព្យាយាមគ្រប់គ្រងព័ត៌មានដែលផ្តល់ឲ្យបុគ្គលិកជាតិ [...] ហើយបានបដិសេធមិនឲ្យបុគ្គលិកជាតិចូលមើលព័ត៌មានទាំងអស់ ទោះបីព័ត៌មានទាំងនោះអាចរកបានក៏ដោយ” [៨៥]។

៤៣. សហមេធាវីការពារក្តីបានតវ៉ាថា ឧប្បត្តិហេតុទាំងនេះនាំឲ្យមានការបំពានលើសិទ្ធិរបស់ជនត្រូវចោទក្នុងការទទួលបានការជំនុំជម្រះដោយតុលាការឯករាជ្យនិងមិនលំអៀង ដែលធានាដោយមាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ សហមេធាវីការពារក្តីបានអះអាងបន្ថែមថា ទ្រឹស្តីអញ្ញមញ្ញនៃការធ្វើសេចក្តីសម្រេច គឺជាគោលការណ៍មូលដ្ឋានរបស់ អ.វ.ត.ក ៖

កឋាខណ្ឌ៣នៃបុព្វកថានៃកិច្ចព្រមព្រៀងបង្កើតតុលាការចែងថា “អាជ្ញាធរកម្ពុជាបានស្នើសុំជំនួយពីអង្គការសហប្រជាជាតិដើម្បីកាត់សេចក្តីមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ [...] មាត្រា ១ នៃកិច្ចព្រមព្រៀងចែងយ៉ាងច្បាស់ពី “កិច្ចសហការ” ដែលជាគោលការណ៍មូលដ្ឋាន។ មាត្រា ៥(៤) នៃកិច្ចព្រមព្រៀងចែងថា “សហចៅក្រមស៊ើបអង្កេតត្រូវសហការគ្នា ដើម្បីឈានទៅដល់ការ

---

[៨៤] សំណើសុំឲ្យធ្វើមោឃភាពកិច្ចស៊ើបសួរ កថាខណ្ឌ៣១។

[៨៥] សំណើសុំឲ្យធ្វើមោឃភាពកិច្ចស៊ើបសួរ កថាខណ្ឌ៣២។



PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE PRELIMINAIRE

ឯកភាពគ្នាមួយ ក្នុងការស៊ើបអង្កេត"។ មាត្រា ២៣ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក បានចែងថា "រាល់ការស៊ើបអង្កេត គឺជាទទួលខុសត្រូវរួមគ្នារបស់ចៅក្រមពីរនាក់ ម្នាក់ជាកម្ពុជា និងម្នាក់ទៀតជាបរទេស [...] ដោយអនុវត្តតាមនីតិវិធីដែលនៅជាធរមាន"[៨៦]។

បន្ទាប់មក សហមេធាវីការពារក្តីបានសន្និដ្ឋានថា ភាគីអន្តរជាតិបាន "បំពានកិច្ចព្រមព្រៀងច្បាប់បង្កើត អ.វ.ត.ក និងវិធានផ្ទៃក្នុងរបស់ខ្លួន"[៨៧] ដោយសារភាគីនេះបានលាក់កំបាំងព័ត៌មានពីភាគីជាតិ។

៤៤. សហមេធាវីការពារក្តីបានលើកឡើងថា "គេអាចសន្មតថាបុគ្គលិកកម្ពុជានៅក្នុង កសចស មានការយល់ដឹងច្រើនលើព្រឹត្តិការណ៍ដែលកើតឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ និងព្រឹត្តិការណ៍នៅកម្ពុជាជាទូទៅ" ភាគីជាតិ "នាំមកនូវការយល់ដឹងដ៏សម្បូរបែបទាក់ទងនឹងប្រវត្តិសាស្ត្រ វប្បធម៌ និងនយោបាយរបស់កម្ពុជា"[៨៨]។ សហមេធាវីការពារក្តីបានអះអាងបន្ថែមថា "ដោយពិចារណាលើការយល់ដឹង ពួកគេមានលក្ខណៈអំណោយផលក្នុងការស្វែងរកភស្តុតាងដោះបន្ទុក" ហេតុដូច្នេះ "ការច្រានចោលបុគ្គលិកម្ពុជានឹងបង្ករការអន្តរាយដល់ជនត្រូវចោទ"[៨៩]។ ម្ចាស់បណ្តឹងអះអាងថា សិទ្ធិដែលត្រូវបានធានាដោយមាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ មាត្រា ៥(៤) នៃកិច្ចព្រមព្រៀង មាត្រា ២៣ថ្មី នៃច្បាប់បង្កើត អ.វ.ត.ក គឺ៖

> "មានគោលបំណងការពារសិទ្ធិរបស់ជនត្រូវចោទ ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ជាពិសេស ករណីនៅ អ.វ.ត.ក ជនត្រូវចោទមានសិទ្ធិក្នុងការឲ្យបុគ្គលិកកម្ពុជា និង បុគ្គលិកអន្តរជាតិស៊ើបអង្កេតលើរឿងក្តីខ្លួន"[៩០]។

៤៥. សហមេធាវីការពារក្តីបានលើកឡើងថា ការបំពានលើសិទ្ធិជាមូលដ្ឋាននេះ នាំឲ្យលទ្ធផលនៃកិច្ចស៊ើបសួរត្រូវចាត់ទុកជាមោឃៈ[៩១]។

---

[៨៦] សំណើសុំឲ្យធ្វើមោឃភាពកិច្ចស៊ើបសួរ កថាខណ្ឌ៣៥។

[៨៧] សំណើសុំឲ្យធ្វើមោឃភាពកិច្ចស៊ើបសួរ កថាខណ្ឌ៣៦។

[៨៨] សំណើសុំឲ្យធ្វើមោឃភាពកិច្ចស៊ើបសួរ កថាខណ្ឌ៣៨។

[៨៩] សំណើសុំឲ្យធ្វើមោឃភាពកិច្ចស៊ើបសួរ កថាខណ្ឌ៣៨។

[៩០] សំណើសុំឲ្យធ្វើមោឃភាពកិច្ចស៊ើបសួរ កថាខណ្ឌ៣៩។

[៩១] សំណើសុំឲ្យធ្វើមោឃភាពកិច្ចស៊ើបសួរ កថាខណ្ឌ៣៩។

* អង្គជំនុំជម្រះសាលាដំបូង * PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE * E.C.C.C * C.E.T.C *

៤៦. តាមការពិនិត្យមើលមូលដ្ឋានពីមុន អង្គបុរេជំនុំជម្រះបានរកឃើញពីថា សហមេធាវីការពារក្តីមិនបានបង្ហាញភស្តុតាងគ្រប់គ្រាន់ដើម្បីគាំទ្រការចោទប្រកាន់ក្នុងមូលហេតុរង (១) ដែលខ្លួនអះអាងថាមានការណែនាំក្នុងកិច្ចប្រជុំថាកុំឱ្យចែករំលែកឯកសារទៅឱ្យបុគ្គលិកជាតិនោះទេ[៥២]។

៤៧. មូលហេតុបន្ទាប់បន្សំ (២) ផ្អែកទៅលើការចងចាំរបស់លោក Bastin អំពីការសន្ទនារវាងគាត់នឹងចៅក្រម យូ ប៊ុនឡេង ដែលគាត់អះអាងថា ក្នុងការសន្ទនានោះ ចៅក្រមរូបនេះ "បានប្រាប់លោក Bastin ថា គាត់បានដឹងថាក្រុមថតខ្សែភាពយន្តបានអមដំណើរអ្នកស៊ើបអង្កេតក្នុងពេលចុះបេសកកម្ម បន្ទាប់ពីរឿងនោះបានកើតឡើងរួចទៅហើយ។ គាត់មិនបានឯកភាពលើកិច្ចការនោះទេ ហើយចៅក្រម Lemonde ក៏មិនបានពិភាក្សាជាមួយគាត់ដែរ"[៥៣]។ បន្ទាប់មកលោក Bastin បាននិយាយថា ចៅក្រម យូ ប៊ុនឡេង បានប្រាប់គាត់ថា មិនមានកិច្ចព្រមព្រៀងរវាង អ.វ.ត.ក និងក្រុមថតខ្សែភាពយន្តទេ ហើយ "ខ្លួនលោកផ្ទាល់មិនដែលបានចុះហត្ថលេខាលើកិច្ចព្រមព្រៀង អនុញ្ញាតឱ្យក្រុមថតខ្សែភាពយន្តធ្វើការជាមួយ កសចស ឡើយ"[៥៤]។ ទឡ្ហីករណ៍របស់សហមេធាវីការពារក្តីផ្អែកលើពាក្យចចាមអារ៉ាមក្នុងសេចក្តីថ្លែងការណ៍លោក Bastin ដែលគ្រាន់តែជាសំដីអះអាង ហើយមិនមែនជាអង្គហេតុដែលមានភស្តុតាងបញ្ជាក់ទេ។

៤៨. ហេតុដូច្នេះ អង្គបុរេជំនុំជម្រះយល់ឃើញថា សេចក្តីថ្លែងការណ៍ទី២ របស់ Bastin មិនបានផ្តល់មូលដ្ឋានអង្គហេតុគ្រប់គ្រាន់ដែលបង្ហាញថាមានកំហុសនីតិវិធីឡើយ។ លើសពីនេះទៅទៀត អង្គបុរេជំនុំជម្រះបានកំណត់រួចហើយថា សេចក្តីថ្លែងការណ៍រួមជាសាធារណៈ ដែល កសចស បានចេញនៅថ្ងៃទី៣ ខែមីនា ឆ្នាំ២០០៨ គឺផ្ទុយពីការចោទប្រកាន់របស់សហមេធាវីការពារក្តីថា កសចស ខ្វែងគំនិតគ្នាលើបញ្ហានេះ"[៥៥]។

៤៩. មូលហេតុបន្ទាប់បន្សំ (៣) ក្នុងមូលដ្ឋាននៃសំណើនេះ ផ្អែកលើការចោទប្រកាន់ថា ចៅក្រម Lemonde បានណែនាំថា មិនត្រូវឱ្យបុគ្គលិកជាតិមើលប្រព័ន្ធទិន្នន័យសាក្សីផ្ទៃក្នុង។ អង្គបុរេជំនុំជម្រះកត់សំគាល់ឃើញថា ក្នុងសេចក្តីថ្លែងការណ៍ទី២ របស់ Bastin លោក Bastin បញ្ជាក់ថា ៖

---

[៥២] ដូចខាងលើ កថាខណ្ឌ៤០។

[៥៣] សេចក្តីថ្លែងលើកទី២របស់ Bastin ទំព័រ៨។

[៥៤] សេចក្តីថ្លែងលើកទី២របស់ Bastin ទំព័រ៨។

[៥៥] សាលដីកាលើបណ្តឹងជំទាស់របស់ អៀង សារី និង អៀង ធីរិទ្ធ កថាខណ្ឌ៦៣។

* អង្គបុរេជំនុំជម្រះ * PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE * E.C.C.C * C.E.T.C *

តាមពិត ទាំងចៅក្រម យូ ប៊ុនឡេង និងទីប្រឹក្សាច្បាប់របស់គាត់ [...] ត្រូវបានផ្តល់លទ្ធភាពឱ្យបើកមើលប្រព័ន្ធទិន្នន័យសាក្សីផ្ទៃក្នុងភ្លាមៗបន្ទាប់ពីបានបង្កើតដោយ [...] ក្នុងឆ្នាំ២០០៧[៥៦]។

សេចក្តីថ្លែងការណ៍ទី២ របស់ Bastin គ្រាន់តែបានចោទប្រកាន់ថា ចៅក្រម Lemonde បានប្រាប់លោក Bastin អំពីការសម្រេចកំហិតលទ្ធភាពបើកមើលប្រព័ន្ធទិន្នន័យសាក្សីផ្ទៃក្នុង។ ការចោទប្រកាន់នេះមិនមែនជាភស្តុតាងគ្រប់គ្រាន់ចង្អុលថាចៅក្រម Lemonde បានចេញសេចក្តីសម្រេចនោះជាឯកតោភាគីឡើយ។ សហមេធាវីការពារក្តីមិនបានផ្តល់មូលដ្ឋានគ្រប់គ្រាន់ដើម្បីគាំទ្រការចោទប្រកាន់ថាភាគីអន្តរជាតិនៃ កសចស បានលាក់កំបាំងព័ត៌មានពីភាគីជាតិឡើយ។ សេចក្តីសម្រេចដែលរងការចោទប្រកាន់ថាកំហិតលទ្ធភាពបុគ្គលិកជាតិក្នុងការបើកមើលឯកសារនោះ គឺជាការសម្រេចផ្ទៃក្នុងដែលអាចត្រូវបានធ្វើឡើងរួមគ្នារវាងសហចៅក្រមស៊ើបអង្កេតទាំងពីររូបសំរាប់មូលហេតុផ្សេងៗ អង្គបុរេជំនុំជម្រះមិនយល់ឃើញថា នយោបាយពាក់ព័ន្ធនឹងលទ្ធភាពបើកមើលប្រព័ន្ធទិន្នន័យផ្ទៃក្នុងរបស់ កសចស អាចបង្កើតបានជាកំហុសនីតិវិធីដែលធ្វើឱ្យអន្តរាយដល់ផលប្រយោជន៍របស់ជនត្រូវចោទឡើយ។

៥០. ហេតុដូច្នេះ អង្គបុរេជំនុំជម្រះសម្រេចបដិសេធចោលមូលហេតុទី៣ នៃសំណើសុំមោឃភាព។

## ឃ. <u>ការរំលោភលើការសម្ងាត់</u>

៥១. សហមេធាវីការពារក្តីបានផ្អែកលើសេចក្តីថ្លែងការណ៍ទី២ របស់ Bastin ហើយចោទប្រកាន់ថា វត្តមានរបស់ក្រុមថតខ្សែភាពយន្តឯកសារបារាំង គឺជាការរំលោភលើការសម្ងាត់។ សហមេធាវីការពារក្តីបានអះអាងថា "សាក្សីត្រូវបានគេថតរូបភាព និងថតសំឡេងយ៉ាងសម្ងាត់ ទោះបីជាគ្មានការយល់ព្រម ឬការអនុញ្ញាតពីសាក្សីរូបនោះក៏ដោយ"[៥៧]។ សហមេធាវីការពារក្តីក៏បានប្រើសេចក្តីថ្លែងការណ៍ទី២ របស់ Bastin ក្នុងការអះអាងថាចៅក្រម យូ ប៊ុនឡេង មិនមែនជាភាគីនៃសេចក្តីសម្រេចដែលអនុញ្ញាតឱ្យក្រុមថតខ្សែភាពយន្ត "ថតការសម្ភាសន៍សាក្សីជាសម្ងាត់"[៥៨] នោះទេ ហើយបន្តថាក្រុមថតខ្សែភាពយន្តដដែលនេះ ត្រូវបានផ្តល់អង្គការលេខរបស់មន្ទីរស-២១ ដែលមានឈ្មោះសាក្សី[៥៩]។

---

[៥៦] សេចក្តីថ្លែងរបស់ Bastin ទំព័រ១០។

[៥៧] សំណើសុំឱ្យធ្វើមោឃភាពកិច្ចស៊ើបសួរ កថាខណ្ឌ៤០។

[៥៨] សំណើសុំឱ្យធ្វើមោឃភាពកិច្ចស៊ើបសួរ កថាខណ្ឌ៥០។

[៥៩] សំណើសុំឱ្យធ្វើមោឃភាពកិច្ចស៊ើបសួរ កថាខណ្ឌ៤១ ដោយយោងទៅលើសេចក្តីថ្លែងការណ៍ទី២របស់ Bastin ទំព័រ៤ និង៦។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

៤២. នៅក្នុងសេចក្តីថ្លែងការណ៍ទី២ របស់គាត់ លោក Bastin បានបញ្ជាក់ថា ក្នុងពេលចុះបេសកកម្មក្នុងខែវិច្ឆិកា ឆ្នាំ២០០៨ គាត់បានទទួលព័ត៌មានពីបុគ្គលិកក្រោមបង្គាប់ថា ក្រុមថតខ្សែភាពយន្តបានអមដំណើរអ្នកស៊ើបអង្កេត និងបានថតការសម្ភាសន៍សាក្សី។ លោក Bastin បានបញ្ជាក់ថា តាមសំដីរបស់បុគ្គលិកក្រោមបង្គាប់របស់គាត់ សាក្សីរូបនោះមិនបានដឹងថាក្រុមថតខ្សែភាពយន្តនោះបានថតការសម្ភាសន៍នោះទេ។ លោក Bastin បាននិយាយថា គាត់បានទៅជួបប្រធានក្រុមស៊ើបអង្កេតដែលប្រធានរូបនោះបញ្ជាក់ថា គាត់បានទទួលព័ត៌មានពីចៅក្រម Lemonde និងប្រធានក្រុមទីប្រឹក្សាក្នុងពេលនោះថា ៖

> "ក្រុមថតខ្សែភាពយន្តបារាំងតែងតែអមដំណើរអ្នកស៊ើបអង្កេត ហើយមានកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សររវាង អ.វ.ត.ក និងក្រុមថតខ្សែភាពយន្តនេះ ដែលចែងថាក្រុមនេះអាចមានលទ្ធភាពក្នុងកិច្ចស៊ើបសួរបាន"[១០០]។

ដោយពឹងផ្អែកលើយោបល់របស់ខ្លួនដែលបានបញ្ជាក់ក្នុងពេលថ្មីៗនេះ លោក Bastin បានបញ្ជាក់ថា ក្រុមថតខ្សែភាពយន្តនេះ មិនត្រូវថតការសម្ភាសសាក្សីទេ ជាពិសេសក្នុងករណីដែលគ្មានការអនុញ្ញាតពីសាក្សី។ លោក Bastin បានរៀបរាប់ថា ប្រធានក្រុមស៊ើបអង្កេតបានពន្យល់ថាខ្លួនអនុវត្តតាមការណែនាំរបស់ចៅក្រម Lemonde និងទីប្រឹក្សាច្បាប់ក្នុងពេលនោះ ដែលជាអ្នកអនុញ្ញាតឱ្យក្រុមថតខ្សែភាពយន្តអមដំណើរអ្នកស៊ើបអង្កេតក្នុងពេលចុះបំពេញបេសកកម្មតាមមូលដ្ឋាន[១០១]។

៤៣. តាមសំដីលោក Bastin សហសេវិកផ្សេងទៀតមិនបានដឹងរឿងនេះទេ ប៉ុន្តែសហសេវិកម្នាក់ពិតជាបានចងចាំពីហេតុការណ៍ពីរដែលបានកើតឡើងមុនលោក Bastin ចូលធ្វើការនៅ កសចស។ ករណីទីមួយនៅពេលប្រធានក្រុមទីប្រឹក្សាច្បាប់ បានណែនាំឱ្យសហសេវិកម្នាក់ផ្សេងទៀតបង្ហាញឯកសារក្នុងប្រព័ន្ធទិន្នន័យទៅក្រុមថតខ្សែភាពយន្ត និងករណីមួយទៀតគឺ នៅពេលដែលក្រុមថតខ្សែភាពយន្តដដែលនេះត្រូវបានផ្តល់អង្គការលេខរបស់មន្ទីរស-២១ដែលមានឈ្មោះសាក្សី[១០២]។ លោក Bastin បានរៀបរាប់ថា គាត់បានសំដែងការព្រួយបារម្ភពីហេតុការណ៍ដែលបានកើតឡើង ក្នុងពេលចុះបេសកកម្ម ក្នុង

---

[១០០] សេចក្តីថ្លែងការណ៍ទី២របស់ Bastin ទំព័រ៥។

[១០១] សេចក្តីថ្លែងការណ៍ទី២របស់ Bastin ទំព័រ៤-៥។

[១០២] សេចក្តីថ្លែងការណ៍ទី២របស់ Bastin ទំព័រ៥-៦។

កិច្ចប្រជុំបុគ្គលិក កសចស ដែលចៅក្រម Lemonde បានចូលរួម[១០៣]។ តាមសំដីលោក Bastin ថា គេបានសុំឱ្យបុគ្គលិកក្រោមបង្គាប់របស់គាត់ រាយការណ៍ពីអ្វីដែលបានកើតឡើងក្នុងពេលចុះបេសកកម្ម ជូនចៅក្រម យូ ប៊ុនឡេង[១០៤]។ បន្ទាប់មក លោក Bastin បានចងចាំពីការប្រជុំមួយរវាងរូបគាត់ជាមួយ ក្រុមថតខ្សែភាពយន្ត ចៅក្រម Lemonde និងប្រធានក្រុមទីប្រឹក្សាច្បាប់ ដែលមានការពន្យល់ថា កំណត់ត្រាវីដេអូ និងខ្សែអាត់សំឡេងនៃការសម្ភាសសាក្សី នឹងត្រូវប្រគល់ជូនផ្នែកគ្រប់គ្រងតុលាការ "រក្សាទុកជាឯកសារ" ហើយ "ផ្នែកគាំពារការការពារក្ដីបានទទួលការណែនាំ ព័ត៌មាន និងបានព្រមព្រៀងលើអ្វីដែលបានកើតឡើងហើយ"[១០៥]។

៥៤. សហមេធាវីការពារក្ដីបានលើកឡើងថា វត្តមានរបស់ក្រុមថតខ្សែភាពយន្តនេះបានបំពានលើវិធាន ៦០(២) នៃវិធានផ្ទៃក្នុង ដែលបានចែងថា "លើកលែងតែការធ្វើការតទល់គ្នា សហចៅក្រមស៊ើបអង្កេតត្រូវស្ដាប់ចម្លើយសាក្សីដោយគ្មានវត្តមានជនត្រូវចោទ ភាគីដទៃទៀត ឬមេធាវី នៅទីកន្លែងណាដែលអាចរក្សាការសម្ងាត់បាន"[១០៦]។ សហមេធាវីការពារក្ដីក៏បានលើកឡើងដែរថា វិធាន ៥៦(១) នៃវិធានក្នុងត្រូវបានបំពាន ដោយសារវិធាននេះបានចែងថា "ការស៊ើបសួរមិនត្រូវធ្វើឡើងជាសាធារណៈឡើយ"[១០៧]។ វិធាន ៥៦ (២)(ខ) ចែងថា "សហចៅក្រមស៊ើបអង្កេតអាចៈ

> ក្នុងកាលៈទេសៈពិសេស ផ្ដល់ការអនុញ្ញាតដោយរួមគ្នាដល់សារព័ត៌មាន ឬអ្នកដទៃទៀតដែលមិនមែនជាភាគីឱ្យចូលរួមដោយមានកម្រិតនៅក្នុងកិច្ចស៊ើបសួរ ដោយការចូលរួមនេះត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យដ៏តឹងរ៉ឹងរបស់ខ្លួន និង បន្ទាប់ពីបានសួរយោបល់របស់ភាគីនៅក្នុងកិច្ចដំណើរការនីតិវិធីនេះ។ ក្នុងករណីមិនគោរពទៅតាមលក្ខខ័ណ្ឌណាមួយដែលសហចៅក្រមស៊ើបអង្កេតតម្រូវ វិធាន ៣៥ ដល់ ៣៨ ត្រូវយកមកអនុវត្ត"[១០៨]។

សហមេធាវីការពារក្ដីបានអះអាងថា អនុវិធាននេះនឹងអនុញ្ញាតឱ្យមានការលើកលែងពីវិធានទូទៅស្ដីពីការរក្សាការសម្ងាត់ តែក្នុងករណីដែលសហចៅក្រមទាំងពីររូបសម្រេចរួមគ្នា។ សហមេធាវីការពារក្ដី

[១០៣] សេចក្ដីថ្លែងការណ៍ទី២របស់ Bastin ទំព័រ៧។
[១០៤] សេចក្ដីថ្លែងការណ៍ទី២របស់ Bastin ទំព័រ៧។
[១០៥] សេចក្ដីថ្លែងការណ៍ទី២របស់ Bastin ទំព័រ៨។
[១០៦] សំណើសុំឱ្យធ្វើមោឃភាពកិច្ចស៊ើបសួរ កថាខណ្ឌ៤២ ដោយយោងទៅលើវិធាន៦០(២) នៃវិធានផ្ទៃក្នុង។
[១០៧] វិធាន៥៦(១) នៃវិធានផ្ទៃក្នុង។
[១០៨] វិធាន៥៦(២)(ខ) នៃវិធានផ្ទៃក្នុង។

ក៏បានលើកឡើងដែរថា ដោយសារក្រុមចតខ្សែភាពយន្ត "មិនពាក់ព័ន្ធនឹងភារកិច្ចតុលាការ"[១០៩] ការផ្តល់ព័ត៌មានសម្ងាត់ទៅឱ្យក្រុមនេះ គឺជាការបំពានលើមាត្រា ១៩ នៃក្រមសីលធម៌ចៅក្រមកម្ពុជាដែលចែងថា "ការប្រើប្រាស់ព័ត៌មានសម្ងាត់ដែលចៅក្រមទទួលបាន ក្នុងគោលបំណងដែលមិនពាក់ព័ន្ធនឹងភារកិច្ចតុលាការ ឬអយ្យការ ត្រូវបានហាមឃាត់"។

៥៥. អង្គបុរេជំនុំជម្រះកត់សំគាល់ឃើញថា សេចក្តីថ្លែងការណ៍ទី២ របស់ Bastin បានរៀបរាប់ពីព័ត៌មានបន្តពីបញ្ហានានាដែលគាត់បានដឹង ជាញឹកញាប់ព័ត៌មានទាំងនោះជាពាក្យចចាមអារ៉ាមដែលចេញពីពាក្យចចាមអារ៉ាម។ ភស្តុតាងដែលបញ្ជាក់ពីអ្វីដែលបានកើតឡើងក្នុងពេលចុះបេសកកម្មនោះ គឺជាព័ត៌មានដែលលោក Bastin បានដឹងដោយផ្ទាល់ មិនមែនជារឿងរ៉ាវដែលគាត់បានឮពីបុគ្គលិកក្រោមបង្គាប់របស់គាត់ ពីសមាជិកផ្សេងទៀតនៃបេសកកម្ម ពីប្រធានក្រុមស៊ើបអង្កេត ឬពីប្រធានក្រុមទីប្រឹក្សាច្បាប់ក្នុងពេលនោះទេ។ មានការអះអាងដែលផ្អែកលើសេចក្តីថ្លែងការណ៍របស់លោក Bastin ថា គេបានតម្រូវឱ្យបុគ្គលិកក្រោមបង្គាប់របស់គាត់រាយការណ៍ជូនចៅក្រម យូ ប៊ុនឡេង ហើយផ្នែកគាំពារការការពារក្តីបានទទួលព័ត៌មានពីហេតុការណ៍នោះហើយ ប៉ុន្តែមិនមានភស្តុតាងគ្រប់គ្រាន់គាំទ្រការអះអាងនេះឡើយ។ ជាពិសេសទៅទៀត ការផ្តល់អង្គការលេខមន្ទីរស-២១ ទៅឱ្យក្រុមចតខ្សែភាពយន្តបានកើតឡើងមុនពេលលោក Bastin ចូលធ្វើការ ហើយរឿងដែលគាត់ដឹងនោះគឺកម្រិតត្រឹមតែអ្វីដែលសហសេវិកម្នាក់ទៀតបានឮ ឬបានជឿជាក់តែប៉ុណ្ណោះ។ អាស្រ័យហេតុនេះ មិនមានភស្តុតាងបញ្ជាក់ថាចៅក្រម Lemonde ពិតជាបានណែនាំផ្ទាល់បែបនោះឡើយ។ ដូចបានបញ្ជាក់ខាងលើដែរ ភស្តុតាងរបស់ Bastin ត្រង់ចំណុចនេះ គឺជាពាក្យចចាមអារ៉ាមដែលចេញពីពាក្យចចាមអារ៉ាម ហើយមិនមែនជាភស្តុតាងគ្រប់គ្រាន់សំរាប់គាំទ្រការចោទប្រកាន់នេះទេ។

៥៦. ហេតុដូច្នេះ អង្គបុរេជំនុំជម្រះសម្រេចបដិសេធមូលហេតុចុងក្រោយនៃសំណើសុំឱ្យធ្វើមោឃភាព។

[១០៩] សំណើសុំឱ្យធ្វើមោឃភាពកិច្ចស៊ើបសួរ កថាខណ្ឌ៤៥។

អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE
E.C.C.C * C.E.T.C

យោងលើសំអាងហេតុទាំងអស់ខាងលើ អង្គបុរេជំនុំជម្រះបានសម្រេចដូចសេចក្តីសម្រេចរបស់ខ្លួន ដែលបានប្រកាសកាលពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១០។

ដោយអនុលោមតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង សាលដីកានេះបិទផ្លូវតវ៉ា។

ភ្នំពេញ ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១០

**អង្គបុរេជំនុំជម្រះ** **ប្រធាន**

**Rowan DOWNING** **នៃយ ថុល** **Catherine MARCHI-UHEL** **ហួត វុទ្ធី** **ប្រាក់ គីមសាន**